សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

KIT

ឧក្រិដ្ឋវិទ្យា

CRIMINOLOGY

ឆ្នាំសិក្សា ២០០៦-២០០៧

បណ្ឌិត សុិន រិទ្ធ

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

KITH

ឧក្រិដ្ឋវិទ្យា

CRIMINOLOGY

ឆ្នាំសិក្សា ២០០៦-២០០៧

បណ្ឌិត សុិន រិទ្ធ

ការសិក្សាឧក្រិដ្ឋវិទ្យា

១. លក្ខណៈទូទៅ និងកម្មវត្ថុឧក្រិដ្ឋវិទ្យា

នីតិស័ព្ទរបស់ពាក្យ "ឧក្រិដ្ឋវិទ្យា" បានមកពី "ឧក្រិដ្ឋ+វិទ្យា"។ បើតាមន័យពាក្យ "ឧក្រិដ្ឋ" មានន័យថា "ធ្ងន់ធ្ងរច្រើន[1]" ក៏ប៉ុន្តែប្រសិនបើសំដៅទៅលើអំពើល្មើសច្បាប់គឺជា "បទឧក្រិដ្ឋ" ដែលក្នុងច្បាប់ព្រហ្មទណ្ឌសម័យ អន្តរកាលឆ្នាំ ១៩៩២ បានបញ្ញត្តិ "បទឧក្រិដ្ឋ" ថាជាបទល្មើសដែលធ្ងន់ធ្ងរជាងគេ។ រីឯពាក្យ "វិទ្យា" មានន័យថាចំណេះដឹង ការយល់ដឹង[2]។ តែបើសិនជាយកលំនាំជាភាសាបរទេសយើងឃើញថា "ឧក្រិដ្ឋ" មានន័យថាដូចពាក្យ "Criment" ជាភាសាឡាតាំង (Latin) សំរាយមកថា "បទល្មើស" ហើយគូបផ្សំនិងពាក្យ "Logos" ដែលជាភាសាក្រិច (Greek) ហៅថា "ការសិក្សា"។ ពាក្យទាំងពីរនេះបូកបញ្ចូលគ្នាមានអត្ថន័យថា "ការសិក្សាបទល្មើស"។ បើនិយាយពីន័យចំខ្លឹមសារនៃការសិក្សាបទល្មើល គ្មានអ្វីអោយពិបាកយល់នោះទេ ។ តែនៅក្នុងឧក្រិដ្ឋវិទ្យាមានន័យទូលំទូលាយ និងស្មុគស្មាញបំផុត។

ម្យ៉ាងទៀតប្រសិនបើឧក្រិដ្ឋវិទ្យាសិក្សាពីបទល្មើស តើច្បាប់ព្រហ្មទណ្ឌសិក្សាពីអ្វីទៅវិញ? ហើយមុខវិជ្ជាពីរផ្សេងគ្នាសិក្សាតែករណីមួយវាមិនជាន់គ្នាទេឬ? ។

ជ្រាកដជាមិនដូច្នោះទេ គោលដៅចម្បងរបស់ឧក្រិដ្ឋវិទ្យាគឺ រិះរកបុព្វហេតុ (Motivation) និងវិធានការទប់ស្កាត់បទល្មើសដែលជាកត្តាសំខាន់បំផុតហើយក៏ជាភាពខុសគ្នារវាងឧក្រិដ្ឋវិទ្យា និងច្បាប់ព្រហ្មទណ្ឌ។ ចំពោះច្បាប់ព្រហ្មទណ្ឌសិក្សាបទល្មើសផ្សេងៗដែលបានកើតឡើងដោយវិភាគទៅលើធាតុផ្សំនៃបទល្មើស ការទទួលខុសត្រូវរបស់ជនល្មើស (Criminal Responsibility) និងការដាក់ទណ្ឌកម្ម(Punishment)អោយសមស្រួមទៅនឹងក្រឹត្យក្រមព្រហ្មទណ្ឌ។ មានទស្សនៈមួយចំនួនយល់ច្រឡំថា ឧក្រិដ្ឋវិទ្យាសិក្សាតែបទល្មើសឧក្រិដ្ឋប៉ុណ្ណោះដោយហេតុថាមានពាក្យឧក្រិដ្ឋនោះ។ គួរកត់សំគាល់ថាដោយសារមានពាក្យឧក្រិដ្ឋ ដូចនេះឧក្រិដ្ឋវិទ្យាមិនត្រឹមតែសិក្សាបទល្មើស

---

[1] ម: ជួនណាត "វចនានុក្រមខ្មែរ" ភាគ ១-២ ការផ្សាយរបស់ពុទ្ធសាសនៈបណ្ឌិតឆ្នាំ១៩៦៨ (ទំព័រ ១១៨២)។

[2] ម: ដដែល (ទំព័រ ១៧៨០)។

នោះទេហើយវាគ្រាន់តែសំណូរនៃពាក្យប៉ុណ្ណោះ។ និយាយរួមឧក្រិដ្ឋវិទ្យានេះសិក្សាគ្រប់បទល្មើសតែជាទូទៅសិក្សាជុំវិញបញ្ហាដែលបណ្តាលឱ្យមានបទល្មើស ក្នុងមជ្ឈដ្ឋាននៃសង្គមដែលជះឥទ្ធិពលគាបសង្កត់លើបុគ្គលអោយប្រព្រឹត្តិបំពានច្បាប់។ ឥទ្ធិពលនេះ និងមានជាកត្តាជីវសាស្ត្រ និង កត្តាសង្គមដែលជាចំណុចសំខាន់។ ក្រៅពីនេះឧក្រិដ្ឋវិទ្យាមានការៈកិច្ចជាបន្តទៀត គឺស្រាវជ្រាវនិងព្រមានបទល្មើស[1] (Criminal Prevention)។

ដូចនេះយើងឃើញថា ក្រៅពីកត្តាសង្គម ឧក្រិដ្ឋវិទ្យាក៏សិក្សាស្រាវជ្រាវភាពខាងក្នុងរបស់បុគ្គល (Individual) ប្រព្រឹត្តបទល្មើសហើយនេះក៏ជាបញ្ហាសំខាន់ផងដែរ។ ការវិភាគលើបាតុភូតសង្គម (Social Phenomenon) ដើម្បីរកបុព្វហេតុនិងការទប់ស្កាត់អំពើល្មើសត្រូវពឹងផ្អែក និងមានទំនាក់ទំនងជាមួយអ្នក ឯកទេសគ្រប់ជំនាញ និងគ្រប់វិស័យ ជាអាទិមានទាំងអ្នកជំនាញវិទ្យា-សាស្ត្រសង្គម និងវិទ្យាសាស្ត្រពិត។ ហេតុដូច្នេះហើយបានជាឧក្រិដ្ឋភាពជានញ្ហាមួយក្នុងចំណោមបញ្ហាដទៃទៀតក្នុងសង្គមដែលតម្រូវអោយគេយកចិត្តទុកដាក់យ៉ាងខ្លាំង និងជាបញ្ហាចម្បងបច្ចុប្បន្ន។

ការផ្តោតអារម្មណ៍របស់អ្នកវិទ្យាសាស្ត្រទៅលើឧក្រិដ្ឋភាព និងឆ្លងតាមទស្សនៈវិភាគបានលេចឡើងនូវមតិផ្ទុយគ្នា (Contradiction) ដោយអ្នកខ្លះវិភាគបទល្មើស និងបុព្វហេតុដោយផ្អែកទៅតាមការវិវត្តន៍របស់សង្គមហើយពោលថា " បទល្មើសហាក់បីដូចជាស្រមោលអន្ទោលតាមប្រាណជាដរាប ហើយដំណាក់កាលវិវត្តន៍របស់សង្គមមិនអាចជៀសផុតពីការកកើតបទល្មើសទេ។ ដូច្នេះទោះជាមានការទប់ស្កាត់តាមរូបភាពណាក៏ដោយ ក៏វានៅតែមានតែក្នុងការស្រមៃប៉ុណ្ណោះ (Abstract) ។ តែការផ្តល់ជាទស្សនៈបែបនេះត្រូវបានឧក្រិដ្ឋវិទូដទៃទៀតបដិសេធទាំងស្រុង និងដោយលើកហេតុផលថា បទល្មើសជាបាតុភូតសង្គមក៏ពិតមែន និងទោះជាភាពសត្យានុម័តរបស់សង្គមក៏ពិតមែនក៏យើងអាចបំប្លែងពីការបង្កអំពើល្មើសអោយទៅជាភាពវិជ្ជមានកាត់បន្ថយជាក៏រឹត ។ក្នុងសង្គមបាន។ ដូចនេះការប្រឆាំងនឹងបទល្មើសត្រូវធ្វើឡើងតាមរូបភាពផ្សេង។ដូចជាផ្សព្វផ្សាយច្បាប់ដល់ពលរដ្ឋ ធ្វើបទឧទ្ទេសនាមអប់រំពលរដ្ឋតាមកន្លែងសាធារណៈការ ផ្សាយព្រឹត្តិប័ត្រអំពីការប្រព្រឹត្តិបទល្មើស ការផ្តត់ផ្តង់ស្ថានភាពអនាចារ ក្មេងអនាថា អំពើអបាយមុខគ្រប់ប្រភេទ។

---

[1] ជាសាមញ្ញហៅថា "វិធានការទប់ស្កាត់បទល្មើស" ។

សព្វថ្ងៃនេះយើងសង្កេតឃើញថា អំពើល្មើសមួយចំនួនបណ្តាលមកពីជម្លោះក្នុងគ្រួសារ[1] ឥទ្ធិពលមជ្ឈដ្ឋានក្នុងស្រទាប់មហាជនដូចជាក្លឹបខាំអូខេ បារ-ឌីស្កូ ក្រុមបងតូចបងធំ ។ល។ ដូច្នេះហើយដើម្បីធានាសុវត្ថិភាព និង សន្តិសុខដល់ពលរដ្ឋបានជារាជរដ្ឋាភិបាលបានចាត់វិធានការដោយអោយបំបាត់នូវការប្រកបអាជីវកម្មតាមរូបភាពខាំអូខេនោះ[2]។ ជាពិសេសរកុមបងធំ និងក្រុមយុវវ័យដែលធ្វើឱ្យខូចសណ្តាប់ធ្នាប់សង្គម។

ម្យ៉ាងវិញទៀតការសិក្សាច្បាប់ព្រហ្មទណ្ឌ និតិវិធីព្រហ្មទណ្ឌ នីតិប្រតិបត្តិព្រហ្មទណ្ឌ ឧក្រិដ្ឋ-និច្ចយ... ។ល។ ក៏ជាការរួមចំណែកមួយនៃវិធានការទប់ស្កាត់ដែរ ថ្វីត្បិតតែមុខវិជ្ជាទាំងនោះផ្តល់ឯកទេសដល់អ្នកច្បាប់ក្នុងការស្វែងយល់វិភាគបទល្មើស[3] និងអនុវត្តទោសក៏ដោយក៏ចាត់ទុកជានយោបាយព្រហ្មទណ្ឌដែរ (Criminal Policy) ។

ជាទូទៅបទល្មើសកើតឡើងដោយពុំមានលក្ខណៈដូចគ្នាទេ។វាកើតឡើងដោយតាមពេលវេលាខុសគ្នា ទីកន្លែងដោយឡែកពីគ្នា បទល្មើសខុសៗគ្នា ។ល។ ចំពោះបុគ្គលប្រព្រឹត្តបទល្មើសក៏មានលក្ខណៈសម្បត្តិមិនដូចគ្នាដែរ។ បច្ចុប្បន្នមានប្រភេទបទល្មើសដែលគួរឱ្យព្រួយបារម្ភដោយសារតែបទល្មើសទាំងនោះបង្កនូវគ្រោះថ្នាក់ដល់សង្គមហួសពីការស្មាន ដូចជាបទល្មើសដែលមានលក្ខណៈជាវិជ្ជាជីវៈបទល្មើសដែលបង្កជាទ្រង់ទ្រាយជាក្រុម។ និងជាពិសេសអំពើភេរវកម្ម ដូចករណី ព្រឹត្តិ-ការណ៍បើកបរយន្តហោះបុកអាគារពាណិជ្ជកម្មពិភពលោកនៅសហរដ្ឋអាមេរិក។ ដូច្នេះឧក្រិដ្ឋភាពដែលបណ្តាលមកពីបទល្មើសទាំងនេះបើចង់ទប់ស្កាត់ គឺទាមទារការវិភាគដោយយកចំណេះដឹងផ្នែកឧក្រិដ្ឋវិទ្យាដោយខានពុំបាន។

ក្នុងនាមជាវិទ្យាសាស្ត្រសង្គម ឧក្រិដ្ឋវិទ្យា ធ្វើការស្រាវជ្រាវដោយយកទ្រឹស្តីជាមូលដ្ឋាន (Objective Knowledge)[4] ផ្សាភ្ជាប់ទៅនឹងភាពជាក់ស្តែងក្នុងសង្គម និងធ្វើការនិទស្សន៍នូវបាតុភូត និងការវិវត្តន៍របស់ឧក្រិដ្ឋភាព។ ការស្រាវជ្រាវរបស់ឧក្រិដ្ឋវិទ្យាទាមទារការប្រមើលនូវបទល្មើសទៅអនាគតដោយប្រៀបធៀបនឹងបទល្មើសបានកើតរួចហើយ។

---

[1] អ្នកជា "បញ្ហាគ្រួសារជាបញ្ហាសង្គម" ព្រឹត្តិប័ត្រអ្នកជា ឆ្នាំ២០០២ ឆ្នាំទី ៩ លេខ២០៣ ចេញថ្ងៃទី១៥ ខែមេសា ឆ្នាំ២០០២ ទំព័រ ៣-៤ និងទំព័រ ១៨-១៩។

[2] ម.: "លិខិតបញ្ជារបស់រាជរដ្ឋាភិបាល" លេខ០១ បប ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០១។

[3] ជាឡាតាំង (Latin) quails មានន័យថា ល្បែងចាត់ផ្សៀនៃបទល្មើសដែលដូចឬក៏ខុសគ្នា ឬប្រហាក់ប្រហែលគ្នា។

[4] តាមឧក្រិដ្ឋវិទ្យា គឺជាការស្វែងយល់ភាពវិជ្ជមានក្នុងសង្គមដោយឆ្នុះបញ្ចាំងភាពសត្យានុម័ត។

សរុបសេចក្តីមក ឧក្រិដ្ឋវិទ្យាជាវិទ្យាសាស្ត្រដែលសិក្សាឧក្រិដ្ឋភាពសិក្សាអត្តសញ្ញាណឧក្រិដ្ឋ-ជនសិក្សាមូលហេតុ និងលក្ខខណ្ឌឧក្រិដ្ឋភាព សិក្សាមធ្យោយបាយនៃការព្រមានឧក្រិដ្ឋភាព។ ផ្អែកលើមូលដ្ឋាននេះ ឧក្រិដ្ឋវិទ្យាធ្វើអនុសាសន៍[1] (Recommendation) ដ៏មានប្រសិទ្ធិភាពចំពោះការប្រឆាំងនឹងឧក្រិដ្ឋភាព។ ក្នុងចំណោមអនុសាសន៍ទាំងនេះ មានអនុសាសន៍ខ្លះបានផ្តល់គំរូដល់អ្នកសេដ្ឋកិច្ច អ្នកសង្គមសាស្ត្រ អ្នកច្បាប់ សំរាប់សិក្សាប្រៀបធៀបក្នុងគោលបំណងបំបាត់ឧក្រិដ្ឋភាពក្នុងសង្គមដោយឆ្លុះបញ្ចាំងសកម្មភាពល្មើសនឹងច្បាប់ដើម្បីការពារ។

ការសិក្សាអ្វីមួយតែងតែមានកម្មវត្ថុដែលត្រូវលើកយកមកវិភាគក្នុងការកំណត់គោលដៅ។ បើគ្មានកម្មវត្ថុទេការសិក្សានឹងមានការស្រពិចស្រពិលហើយ និងពិបាកទទួលបានលទ្ធផល។ ដូច្នេះការស្រាវជ្រាវដោយផ្សារភ្ជាប់នឹងសង្គមមានការវិវត្តន៍ជាបន្តបន្ទាប់រហូតដល់មានជាស្មាដៃរបស់ឧក្រិដ្ឋវិទូហើយហៅថា "ឧក្រិដ្ឋវិទ្យាសង្គម"[2]។ សារៈសំខាន់នៃសមិទ្ធិផលនេះបានផ្តោតបញ្ហាស្ថានភាពសង្គមជាចំបង។ មិនត្រឹមតែប៉ុណ្ណោះ ត្រូវការលុបបំបាត់នូវភាពអាណូមី (ANOMIA) ក្នុងសង្គម ជាពិសេសភាពអយុត្តិធម៌ អំពើពុករលួយ ប្បែរវិវត្សមន្ត្រីរាជការ លើកដម្កើងទាំងស្មារតី និងទាំងសំភារៈ និងធ្វើយ៉ាងណាផ្តល់ជីវភាពសមស្របតម្រូវការ។ យោងតាមទស្សនៈឧក្រិដ្ឋវិទូក្នុងការបំបាត់អាណូមី ក្នុងសង្គមយើងឃើញមានការកែប្រែទម្រង់រដ្ឋបាល និងអភិបាលកិច្ចល្អ[3] ដើម្បីស្តារប្រទេសជាតិយើងអោយមានភាពរីកចម្រើនតាមលទ្ធិប្រជាធិបតេយ្យពិត។ ដូច្នេះឧក្រិដ្ឋវិទ្យាក៏មានកម្មវត្ថុរបស់វា គ្រាន់តែកម្មវត្ថុនេះមានភាពអរូបីយ៉ាដែលយើងគ្រាន់តែប្រមើមើលឆ្លងកាត់ច្បាប់ជាទូទៅ។ កម្មវត្ថុរបស់ឧក្រិដ្ឋវិទ្យាមានដូចខាងក្រោម :

ក-ឧក្រិដ្ឋភាព : ប្រវត្តិសាស្ត្របង្ហាញឱ្យឃើញថា បើសង្គមមានការប្រែប្រួលច្បាប់ក៏មានការប្រែប្រួលដែរ។ នេះសបញ្ជាក់ថាបទល្មើសជាបាតុភូតអាស្រ័យ នឹងសង្គមកម្ម និងបានកើតឡើងក្នុងពេលកំណត់ហើយមានភាពខុសៗគ្នាតាមប្រភេទបទល្មើសតាមកម្មវត្ថុដែលបំពានលើតាមតំបន់មានបទល្មើស តិច ឬច្រើន ។ល។ នៅក្នុងជីវភាពជាក់ស្តែងដូចជា នៅកម្ពុជាសព្វថ្ងៃឧក្រិដ្ឋភាព

---

[1] L. recommendation, Eng. recommendation មានន័យថាការតបដ៏ល្អជាលាយលក្ខណ៍អក្សរឬដោយផ្ទាល់មាត់។ នៅក្នុងឧក្រិដ្ឋវិទ្យាសំដៅទៅលើសេចក្តីសន្និដ្ឋានដែលបានមកពីធ្វើការស្រាវជ្រាវសំរាប់យកទៅវិភាគ និងអនុវត្ត ដែលចាប់ទុកថាជាអនុសាសន៍។

[2] Totowa. "Radical Issues in Criminology". 1980. P. 8.

[3] កម្ពុជា "ការស្រាវជ្រាវអភិបាលកិច្ច និងអំពើពុករលួយ" ខែមេសា ឆ្នាំ២០០១។ "ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល". ព្រឹត្តិប័ត្រពត៌មាន ខែកុម្ភៈ-មិនា ឆ្នាំ២០០២ ឆ្នាំទី២ លេខ ០១២

មានការកើនឡើងដោយសន្ទុះយ៉ាងលឿន។ ឧទាហរណ៍ : ចោរកម្ម សកម្មភាពពេស្យាចារ ភាពពុករលួយ និងម្យ៉ាងរហូតដល់យើងធ្វើវិសោធនកម្មនៃបទល្មើសដោយបង្កើនស្ថានទម្ងន់ទោស ដើម្បីទប់ស្កាត់[1] បទល្មើសមួយផ្នែកទៀតបានកើតឡើងដោយសារតែធាតុអវិជ្ជមានក្នុងសង្គម ដូចជា ការប្រមឹក ភាពបញ្ឆើរក្អែក ការប្រើប្រាស់ គ្រឿងញៀនដែលសង្គមមិនត្រូវការ។

ឧក្រិដ្ឋភាពដែលយើងសិក្សានេះគឺវិភាគរកមូលហេតុនិងលក្ខខណ្ឌនៃការបង្កបទល្មើស និងធ្វើការព្រមានសំរាប់អនាគតយើងមិនសិក្សាក្នុងនាមជាច្បាប់ព្រហ្មទណ្ឌទេ ហេតុដូច្នេះហើយបានជាវាមិនមែនជានិតិ ។

ឧក្រិដ្ឋវិទ្យាខុសពីទស្សនៈវិជ្ជា ពីព្រោះវាសិក្សាឧក្រិដ្ឋភាព តាមស្ថានភ្ញាភាពទីកន្លែង និងពេលវេលានៅក្នុងដែនកំណត់ជាក់លាក់។

ខ-អត្តសញ្ញាណឧក្រិដ្ឋជន : មានសារៈសំខាន់ណាស់នៅក្នុងឧក្រិដ្ឋវិទ្យា បើគ្មានកម្មវត្ថុនេះទេ ការព្រមានឧក្រិដ្ឋភាពក៏មិនអាចធ្វើទៅកើតដែរ។ អត្តសញ្ញាណឧក្រិដ្ឋជនដែលកម្មវត្ថុឧក្រិដ្ឋវិទ្យា គឺជាជីវប្រវត្តិ និងចិត្តសាស្ត្ររបស់បុគ្គលប្រព្រឹត្តបទល្មើស។ វិធានការទាំងឡាយដែលអនុវត្តចំពោះអត្តសញ្ញាណឧក្រិដ្ឋជន គឺធ្វើឡើងដោយផ្អែកទៅលើពតិមានស្តីពីមូលហេតុរបស់បទល្មើស។ ការស្រាវជ្រាវអត្តសញ្ញាណមានទិសដៅវិភាគជីវប្រវត្តិ និងចិត្តសាស្ត្ររបស់ឧក្រិដ្ឋជនមុនពេលប្រព្រឹត្តបទល្មើស ពេលប្រព្រឹត្តបទល្មើស និងក្រោយពេលប្រព្រឹត្តបទល្មើស។

គ-មូលហេតុ និង លក្ខខណ្ឌ : ឧក្រិដ្ឋភាពមានការវិវត្តន៍ អាស្រ័យនឹងស្ថានភាពសង្គមដូចជា ស្ថានភាពសេដ្ឋកិច្ច ស្ថានភាពនយោបាយរដ្ឋ ស្ថានភាពគ្រួសារ ស្ថានភាពបុគ្គល ។ល។ ស្ថានភាពទាំងនេះ ជាលក្ខខណ្ឌដែលជំរុញឱ្យមានបទល្មើស រីឯបទល្មើសទាំងនោះមានលក្ខណៈខុសគ្នាទៅតាមពេលតាមតំបន់ និងតាមកាលៈទេសៈហើយពេលខ្លះទៀតកើតឡើងដោយចៃដន្យ។

ឃ-ការព្រមាន : ជាវិធានការដែលមានទិសដៅលុបបំបាត់បទល្មើស បំបាត់មូលហេតុដែលនាំឱ្យកើតបទល្មើសវិភាគ និងធ្វើការនិទស្សន៍បទល្មើសសិក្សាស្ថិតិនៃបុព្វហេតុជាដើម។

កម្មវត្ថុឧក្រិដ្ឋវិទ្យាទាំងបួន មានទំនាក់ទំនងគ្នាយ៉ាងជិតស្និត ដែលការសិក្សាមិនអាចបោះបង់ណាមួយបាន ពីព្រោះឧក្រិដ្ឋវិទ្យាស្ថិតក្នុងជំពូកវិទ្យាសាស្ត្រដទៃទៀត ដើម្បីសំរេចបំណងរបស់ខ្លួន។

---

[1] ម. "ច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ" ។ ព្រះរាជក្រមលេខ នស/រកម/០១០២/០០៤ ចុះថ្ងៃទី៧ ខែមករា ឆ្នាំ២០០២។

២. ការវិវឌ្ឍន៍ឧក្រិដ្ឋវិទ្យា

ឧក្រិដ្ឋវិទ្យា ត្រូវបានគេសិក្សាតាំងពីសម័យមុនគ្រឹះសករាជមកម្ល៉េះ ហើយបានបន្សល់ទុកនូវទស្សនៈស្តីពីការកកើតបទល្មើសក្នុងសម័យនោះ។ ថ្វីត្បិតតែសម័យនោះពុំមានស្ថាប័នរដ្ឋពុំមានការគ្រប់គ្រងជាលក្ខណៈរដ្ឋ និងពុំមានយន្តភាពរដ្ឋត្រឹមត្រូវក៏ពិតមែន ក៏ការគ្រប់គ្រងឋិតក្នុងលក្ខណៈមួយមានមេកន្ត្រាញ មានក្រុមមានពួក។ ជីវភាពរស់នៅក្រោមច្បាប់ព្រៃធ្វើឱ្យពួកគេដោះស្រាយជម្លោះដោយបង្ហូរឈាមក្នុងការទាមទារអ្វីមួយ។ លក្ខខណ្ឌនៃមជ្ឈដ្ឋានបានក្បៀបសង្កត់ និងជំរុញឱ្យពួកគេមានការគុំគួនគ្នារហូតដល់មានការកាប់សំលាប់គ្នា។ ផ្អែកលើស្ថានភាពបែបនេះទស្សនៈឧក្រិដ្ឋវិទ្យាបានបន្សល់ទុកនូវសេចក្តីសន្និដ្ឋានជាមូលហេតុឧក្រិដ្ឋភាពមានពីរយ៉ាង :

- គំនុំសងឈាម។
- ការដណ្តើមអំណាចគ្នា។

ទស្សនៈឧក្រិដ្ឋវិទ្យានេះ បានបន្សល់ទុកនៅយុគសម័យមុនដូចជា : អេហ្សីប .ឥណ្ឌា ជាដើម។ នៅប្រទេសចិនយុគ្គសម័យមុនបានបន្សល់ទុកទស្សនៈថា : ការគ្រប់គ្រងមនុស្សមិនត្រូវធ្វើឡើងដោយចិត្តសប្បុរសធម៌ទេ (ង្វៀងមុញយ៉ាង) ។ ក្នុងភាពជាក់ស្តែងបើយើងក្រឡេកមើលមនោគមវិជ្ជាស្តាលីន ម៉ៅសេទុង ប៉ុលពត ឃើញថាអនុវត្តបានជោគជ័យក្នុងការទប់ស្កាត់បទល្មើស។ បានសេចក្តីថា រដ្ឋត្រូវប្រើអំណាចគ្រប់កាលៈទេសៈ ក្នុងការគ្រប់គ្រងពលរដ្ឋ បើពុំដូច្នេះទេពុំអាចធានាសន្តិសុខក្នុងសង្គមបានឡើយ។ ប៉ុន្តែកំភ្លេចថាលទ្ធិ Absolute ដូចប៉ុលពត និងមានប្រតិកម្មដែលការអត់ធ្មត់របស់មហាជនមិនអាចបន្តទៀត។ ចំពោះលោក កុងហ្វូស៊ី បានគិតថា "បើការអប់រំមានលក្ខណៈល្អ" អាចឱ្យមនុស្សយល់ខុសត្រូវបាន។ ក្នុងគ្រួសារ ក្នុងសង្គម បើពុំយកចិត្តទុកដាក់ពីបញ្ហានេះទេនឹង មានវិបត្តិធ្ងន់ធ្ងរណាស់។ ការអប់រំក្នុងសង្គមកម្ពុជានៃជំនាន់លោកក្រមង៉ុយលោកបានបន្សល់ទុកនូវពាក្យប្រៀនប្រដៅ ជាកំណាព្យកាព្យឃ្លោងដល់កូនខ្មែរជាច្រើន។ ប្រសិនបើយើងវិភាគតាមឧក្រិដ្ឋវិទ្យាវាបង្ហាញឱ្យឃើញថាការអប់រំកូនខ្មែរសំរាប់លោកង៉ុយមានសារៈសំខាន់ហើយអាចជៀសផុតពីការប្រព្រឹត្តខុសច្បាប់ ។ បើយើងប្រៀបធៀបមកបច្ចុប្បន្ននៃសង្គមកម្ពុជាទស្សនៈអប់រំចាត់ទុកថាត្រឹមត្រូវទេ[1] ? ម្យ៉ាងទៀតប្រសិនបើ យើងក្រឡេកមើលសង្គមខ្មែរសម័យសង្គម

---

[1] ម.អគ្គបទ (ខ្ញុំមិនមានសំណាងដូចក្មេងដ៏ទៃទេ) ។ ទស្សនាវដ្តីប្រជាប្រិយ ឆ្នាំទី៥ លេខ ១១០៨១ ១-១៥ មិថុនា ១៩៩៩ (ទំព័រ ១១) ។

ដែលគ្រប់គ្រងដោយព្រះបាទជ័យវរ្ម័នទី៧ ព្រះអង្គយកចិត្តទុកដាក់ចំពោះការអប់រំ[1] ហេតុដូច្នេះ ហើយបានជាសម័យនោះមានភាពថ្កុំថ្កើង។ ការអប់រំ ជាកត្តាសំខាន់ណាស់ក្នុងសង្គម បើរដ្ឋពុំយកចិត្តទុកដាក់ទេសង្គមនឹងមានវិបត្តិដោយសារភាពអនាធិបតេយ្យរីឯបទល្មើសនឹងកកើតឡើងជាពុំខាន។

សម័យមុនការស្រាវជ្រាវខាងឧក្រិដ្ឋវិទ្យា បានវិភាគរកមូលហេតុឧក្រិដ្ឋភាព ដោយសង្កត់ធ្ងន់ទៅលើចិត្តសាស្ត្រមនុស្ស និងបាតុភូតសង្គម។ លក្ខណៈទាំងពីរនេះជាមូលដ្ឋានផ្តល់ការកៀបសង្កត់ដល់បុគ្គលិកលក្ខណៈរបស់ បុគ្គលឱ្យប្រព្រឹត្តបទល្មើស[2]។ ម្យ៉ាងទៀតការព្រមានបទល្មើសក្នុងយុគសម័យនោះក៏មានតួនាទីសំខាន់ដែរ។ គេចាត់ទុកថាទណ្ឌកម្ម ជាវិធានការមួយដែលធ្វើឱ្យមនុស្សរាងចាលពីការល្មើស។ ឧទាហរណ៍ : ដូចជានៅសម័យបុព្វកាល ឥណ្ឌាមានច្បាប់ "មានូ" ដែលនិយាយពីទណ្ឌកម្ម។ ទណ្ឌកម្មនៃច្បាប់នោះបានជំរុញឱ្យគេគោរពជំនឿជាពិសេសជឿលើអាទិទេព។ ការបង្ខំឱ្យមនុស្សខ្លាចទណ្ឌកម្មជាគោលបំណងអ្នកគ្រប់គ្រង ដែលចង់រក្សាអំណាចរបស់ខ្លួនឱ្យមានស្ថេរភាពដោយចៀសវាងនូវការកកើតបទល្មើសផ្សេងៗ។

ខ្លឹមសារដូចបានអធិប្បាយខាងលើ ជាលក្ខណៈសិក្សាឧក្រិដ្ឋវិទ្យានៃសម័យបុព្វកាល។ នៅសតវត្សទី XIX ការសិក្សាឧក្រិដ្ឋវិទ្យាមានភាពជឿនលឿន។ ការវិឌ្ឍន៍តាំងពីដើមរហូតដល់សតវត្សទី XIX ឧក្រិដ្ឋវិទ្យាបានក្លាយជាវិទ្យាសាស្ត្រសង្គម និងសិក្សាពីឧក្រិដ្ឋភាពដោយបែងចែកការស្រាវជ្រាវជាបួនប្រភេទ[3] :

ក. ការស្រាវជ្រាវលើមនុស្ស។

ខ. ស្រាវជ្រាវលើស្ថិតិ។

គ. ស្រាវជ្រាវលើសេដ្ឋកិច្ចសង្គម។

ឃ. ស្រាវជ្រាវលើច្បាប់ក្នុងសង្គម។

ដូច្នេះយើងឃើញថា ការសិក្សាឧក្រិដ្ឋវិទ្យានៅចុងសតវត្សទី ១៩ មានការរីកចំរើនខ្លាំង។ ឧក្រិដ្ឋវិទ្យាជាវិទ្យាសាស្ត្រមិនឯកនៅក្នុងនីតិព្រហ្មទណ្ឌតែវាមានទំនាក់ទំនងជាមួយវិទ្យាសាស្ត្រនីតិ-ព្រហ្មទណ្ឌ។ ការសិក្សាឧក្រិដ្ឋភាព ឧក្រិដ្ឋជនជាតួនាទីឧក្រិដ្ឋវិទ្យា។ រីឯវិធានការទប់ស្កាត់បទល្មើស

---

[1] ម.អត្ថបទ (សង្គមខ្មែរ ខ្វះសីលធម៌បន្ទោសអ្នកណា?)។ ទស្សនាវដ្តីកំសាន្តសប្តាហ៍នេះ ឆ្នាំទី៣ លេខ ៦៥ ២១-២៧ មិថុនា ១៩៩៩ (ទំព័រ ៨)។

[2] ដូចទស្សនៈរបស់លោក Platon, Aristot, Siseron ជាដើម។

[3] H. Gall. Sur Les fontior du cerveau T.1, 1825

ជានយោបាយព្រហ្មទណ្ឌ[1] ។ ការសិក្សារបស់ឧក្រិដ្ឋវិទ្យាពីបទល្មើសបែងចែកមជ្ឈដ្ឋានដែលត្រូវសិក្សាជាពីរប្រភេទ។

(១). ឧក្រិដ្ឋភាពជីវៈ ដែលសិក្សាលក្ខណៈសម្បត្តិខាងក្នុង ។

(២). ឧក្រិដ្ឋភាពសង្គម ដែលសិក្សាមជ្ឈដ្ឋានខាងក្រៅ ។

មជ្ឈដ្ឋានទាំងពីរនេះមានឥទ្ធិពលទៅវិញទៅមកជានិច្ច ។

សរុបសេចក្តីមក ឧក្រិដ្ឋវិទ្យាស្ថិតនៅក្នុងប្រព័ន្ធវិទ្យាសាស្ត្រ ដូចវិទ្យាសាស្ត្រដទៃទៀតដែរ ពីព្រោះ :

- ឧក្រិដ្ឋវិទ្យា ជាវិទ្យាសាស្ត្រសង្គម ។
- ផ្តល់ចំណេះដឹងដ៏ទូលាយដល់អ្នកឯកទេស ។
- មានទំនាក់ទំនងជាមួយវិទ្យាសាស្ត្រដទៃទៀត ។
- ជាមុខវិជ្ជាមួយ ដែលទូទាំងពិភពលោកស្វែងយល់ ។

៣. <u>ទីធីសាស្ត្រឧក្រិដ្ឋវិទ្យា</u> (Method of criminology)

ក- អត្ថន័យវិធីសាស្ត្រ

វិធីសាស្ត្រឧក្រិដ្ឋវិទ្យា គឺជាក្បួន មធ្យោបាយ និងជាឧបករណ៍សំរាប់ស្រាវជ្រាវវិភាគពីឧក្រិដ្ឋភាពមូលហេតុ និង លក្ខខណ្ឌរបស់ឧក្រិដ្ឋភាព និងការព្រមានចំពោះបទល្មើស ។ ក្រោយពីស្រាវជ្រាវចប់ត្រូវមានសេចក្តីសន្និដ្ឋានអំពីភាពជាក់ស្តែងក្នុងសង្គម និងធ្វើជាសំណើ ឬធ្វើជាអនុសាសន៍ (Recommendation) សំរាប់អ្នកសិក្សាបទល្មើស អ្នកប្រឆាំង និងបទល្មើសយកទៅអនុវត្ត ។

យើងដឹងហើយថា ឧក្រិដ្ឋវិទ្យាមានលក្ខណៈអរូបិយ៍ក៏ប៉ុន្តែឧក្រិដ្ឋវិទ្យាមានសារៈសំខាន់ណាស់សំរាប់ការរីកចំរើនរបស់សង្គម ។ បច្ចុប្បន្នឧក្រិដ្ឋវិទ្យាមានភារកិច្ចចំបងបី <u>ទីមួយ</u>ការពារការរំលោភច្បាប់ ។ <u>ទីពីរ</u> វិភាគរកមូលហេតុបទល្មើស និង <u>ទីបីគឺ</u> ផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវសំរាប់អ្នកអនុវត្តដោយធ្វើជាសំណើ ឬអនុសាសន៍ក្នុងកិរិតបច្ចេកទេស ។

---

[1] គេប្រើពាក្យ (នយោបាយព្រហ្មទណ្ឌ) ក្នុងន័យធ្វើការប្រឆាំងនឹងបទល្មើស។ មានន័យពីឯករាជ្យបីប្រភេទចូលរួមធ្វើការប្រឆាំង : នីតិព្រហ្មទណ្ឌ នីតិវិធីព្រហ្មទណ្ឌ និងនីតិប្រតិបត្តិព្រហ្មទណ្ឌ។

ដើម្បីឱ្យភារកិច្ចទាំងនេះបានសំរេច និងទទួលបាននូវលទ្ធផលល្អនៅក្នុងវិធីសាស្ត្ររបស់ឧក្រិដ្ឋវិទ្យាដាច់ខាតត្រូវមានអ្នកឯកទេសផ្សេងទៀតចូលរួមធ្វើការស្រាវជ្រាវ។ អ្នកទាំងនោះមានដូចជា អ្នកច្បាប់ អ្នកសង្គមសាស្ត្រ អ្នកសេដ្ឋកិច្ច អ្នកចិត្តសាស្ត្រ ។ល។ ការចូលរួមរបស់អ្នកជំនាញផ្សេងៗគ្នាទាំងនេះគឺត្រូវស្រាវជ្រាវតាមកម្មវត្ថុ ដែលទាក់ទងនឹងការល្មើសក្នុងសង្គម។ ឧទាហរណ៍ : សិក្សាស្រាវជ្រាវពីបទល្មើសទាក់ទងទ្រព្យសម្បត្តិ[1] ត្រូវមានអ្នកជំនាញខាងសេដ្ឋកិច្ច និងអ្នកជំនាញខាងចិត្តសាស្ត្រ។ ចំណេះដឹងផ្នែកសេដ្ឋកិច្ចក្នុងករណីនេះចូលរួមវិភាគស្ថានភាពសេដ្ឋកិច្ចសង្គម និងស្ថានភាពគ្រួសាររបស់ជនល្មើសទៅតាមជីវភាពជាក់ស្តែង ។ រីឯចំណេះដឹងផ្នែកចិត្តសាស្ត្រត្រូវការវិភាគអត្តសញ្ញាណឧក្រិដ្ឋជនផ្នែក ស្មារតី អារម្មណ៍ ជាដើម។

យើងដឹងហើយថា ឧក្រិដ្ឋវិទ្យាជាវិទ្យាសាស្ត្រសង្គម ដូច្នេះលក្ខណៈវិធីសាស្ត្រនៃការស្រាវជ្រាវត្រូវ ផ្អែកលើទ្រឹស្តីសង្គម និងទ្រឹស្តីនីតិ។ ល្អីកណាគ្មានការវិភាគដោយផ្អែកលើមូលដ្ឋាននោះទេ នោះការធ្វើការប្រឆាំងនឹងឧក្រិដ្ឋ ភាពមិនអាចមានប្រសិទ្ធិភាពបានឡើយជាទូទៅការអនុវត្តន៍វិធី-សាស្ត្ររបស់ឧក្រិដ្ឋវិទ្យាទាក់ទងនឹងបទដ្ឋានច្បាប់ហើយមិនត្រឹមតែច្បាប់ព្រហ្មទណ្ឌ នីតិវិធីព្រហ្មទណ្ឌ និងប្រតិបត្តិព្រហ្មទណ្ឌប៉ុណ្ណោះទេ គឺថែមទាំងច្បាប់រដ្ឋប្បវេណី ច្បាប់រដ្ឋបាលថែមទៀត។ ក្នុងការស្រាវជ្រាវរបស់ឧក្រិដ្ឋវិទ្យាជាញឹកញាប់ ប្រើប្រាស់វិធីរបស់អ្នកសង្គមវិទូ ដូចជា អនុត្តស្ថិតិវិធី ទំរង់វិធី ការសំភាសន៍ ការវាយតំលៃនៃកោសល្យវិច្ច័យ ។ល។ វិធីទាំងអស់នេះឧក្រិដ្ឋវិទ្យាអនុវត្តក្នុងការស្រាវជ្រាវលើឧក្រិដ្ឋភាព និងបានជោគជ័យជាទីបំផុត។

- ការត្រៀមលក្ខណៈធ្វើការស្រាវជ្រាវឧក្រិដ្ឋភាព :

ក- ជំហានដំបូងនៃការស្រាវជ្រាវ ទាមទារនូវការរៀបចំឱ្យបានគ្រប់ជ្រុងជ្រោយ ដូចជាប្រមូលឯកសារជាដើមការវាយតំលៃ (Valuation) លទ្ធផលរបស់អ្នកជំនាញផ្សេងៗដែលប្រមូលបានធ្វើសេចក្តីសន្និដ្ឋានផ្អែកតាមឯកសារដើមដែលទទួលបាន និងធ្វើគំរោង និងសំណើសំរាប់ធ្វើការស្រាវជ្រាវទៅលើប្រធានបទដែលចង់បាន។ ប្រធានបទដែលដាក់សំរាប់ធ្វើការស្រាវជ្រាវដាច់ខាតត្រូវបង្ហាញឱ្យឃើញថាវាជាបញ្ហាសំខាន់បំផុត។ ឧទាហរណ៍ : ឧក្រិដ្ឋភាពស្ត្រីជាប្រធានបទមួយដែលនឹងត្រូវធ្វើការស្រាវជ្រាវ។ ដូច្នេះជាបឋមត្រូវពិនិត្យមើលថាតើបញ្ហានេះពីមុនមកគេបានធ្វើ

---

[1] គឺជាលក្ខណៈបទល្មើសដែលប៉ះពាល់ទៅលើទ្រព្យអ្នកដទៃ។

ការស្រាវជ្រាវឬទេ ? បើបានធ្វើការស្រាវជ្រាវ តើលទ្ធផល នោះបែបណា? រីឯសំណើ ឬអនុសាសន៍មានដែរឬគ្មាន ? និងជាពិសេសត្រូវពិនិត្យមើលការអនុវត្តន៍ក្រោយពីបានធ្វើការស្រាវជ្រាវមានប្រសិទ្ធិភាពដូចម្តេចខ្លះ? ។

ខ- ក្រោយពីធ្វើការរៀបចំស្រាវជ្រាវរួចហើយត្រូវកំណត់ទិសដៅ និងភារកិច្ចដើម្បីស្រាវ-ជ្រាវ។ ក៏ប៉ុន្តែការកំណត់ទិសដៅ និងភារកិច្ចអាស្រ័យនឹងកត្តារៀបចំសំរាប់ធ្វើការស្រាវជ្រាវ ដូចជាអ្នកដឹកនាំស្រាវជ្រាវការប្រើប្រាស់កំលាំង និងមធ្យោបាយការប្រើប្រាស់ប្រភពពត៌មាន និងលក្ខខណ្ឌផ្សេងៗទៀតដែលទាក់ទងនឹងការស្រាវជ្រាវឧក្រិដ្ឋភាព។ ជាទូទៅឧក្រិដ្ឋវិទ្យាស្រាវជ្រាវធ្វើឡើងដោយក្រុមឧក្រិដ្ឋវិទូ និង អ្នកអនុវត្តដោយយោងទៅតាមគំរោងស្រាវជ្រាវបែបវិទ្យាសាស្ត្រ។

គ- ទំហំ និងបរិមាណរបស់ឧក្រិដ្ឋវិទ្យាស្រាវជ្រាវ ត្រូវកំណត់ទៅតាមទិសដៅ និងភារកិច្ចដែលត្រូវស្រាវជ្រាវ និងជាពិសេសវាអាស្រយ័នឹងកម្មវត្ថុស្រាវជ្រាវ ដំណាក់កាលស្រាវជ្រាវ ដែនដីនិយាយរួមឱ្យតែអ្វីដែលស្ថិតនៅក្រោមការស្រាវជ្រាវ។ ប៉ុន្តែក្នុងករណីនេះចាំបាច់ត្រូវតែវិភាគស្ថានភាពសេដ្ឋកិច្ចនៅក្នុងដំណាក់កាលដែលស្រាវជ្រាវ។

ឃ- នៅក្នុងកម្មវិធីស្រាវជ្រាវត្រូវយកចំណេះដឹងទ្រឹស្តីផ្សារភ្ជាប់នឹងភាពជាក់ស្តែងដើម្បីធ្វើការស្រាវជ្រាវ។ គ្រប់អក្សរសិល្ប៍ដែលពាក់ព័ន្ធត្រូវយកមកអនុវត្ត ។ ចំពោះប្រភពពត៌មានស្តីពីឧក្រិដ្ឋភាព គឺ ស្ថិតព្រហ្មទណ្ឌ[1] (Criminal Statistics) ដែលផ្តល់ពត៌មានស្តីពីសកម្មភាពស្ថាប័នការពារសន្តិសុខ ប្រឆាំងនឹងបទល្មើស ក្នុងនោះមាន ការព្រមានបទល្មើសផ្ទាល់តែម្តង។ ស្ថិតព្រហ្ម-ទណ្ឌមានសារៈប្រយោជន៍ក្នុងការស្រាវជ្រាវព្រោះថាបង្ហាញបរិមាណបទល្មើស និងបុគ្គលប្រព្រឹត្តបទល្មើស។ ដូច្នេះតាមប្រភពនេះយើងអាចវាយតំលៃបីយ៉ាងគឺ ទី១ វាយតម្លៃទៅលើបទល្មើស និង ទី២ វាយតម្លៃទៅលើបុគ្គលប្រព្រឹត្តបទល្មើស និង ទីបីគឺ ទណ្ឌកម្មដែលបានផ្តន្ទាទោស។

សរុបសេចក្តីមក វិធីសាស្ត្រឧក្រិដ្ឋវិទ្យាស្រាវជ្រាវជាវិធីដែលមានលក្ខណៈពិបាក។ ផ្អែកលើមូលដ្ឋានទ្រឹស្តី វិធីនេះវិភាគតាមមូលសាស្ត្រ :

. វិភាគបទល្មើស ក្នុងមជ្ឈដ្ឋានសង្គមដោយប្រើវិធីសាស្ត្រដូចជា សង្គមសាស្ត្រ ចិត្តសាស្ត្រ។

---

[1] ជាទូទៅស្ថិតព្រហ្មទណ្ឌបានមកពីប្រភពបទល្មើស (Crime statistics) និងស្ថិតិតុលាការ (Judical statistics)

*** Eng. principle : នៅក្នុងទ្រឹស្តីវិស័យច្បាប់ គេប្រើពាក្យចូលសាស្ត្រ។

- ការវិភាគឧក្រិដ្ឋភាព គឺវិភាគបាតុភូតដែលមានទំនាក់ទំនងជាមួយបទល្មើស។ កត្តានេះចាំបាច់ណាស់ត្រូវស្រាវជ្រាវមជ្ឈដ្ឋានក្នុង និងមជ្ឈដ្ឋានក្រៅឧក្រិដ្ឋភាព។ មជ្ឈដ្ឋានក្នុងបទល្មើស គឺសំដៅទៅលើអត្តសញ្ញាណនៃការល្មើស និងសិក្សាវិភាគដោយលំអិតជាទីបំផុត។ មជ្ឈដ្ឋានក្រៅបទល្មើស គឺជាសង្គម និង ស្ថានភាពសង្គមដែលជំរុញឱ្យមានការប្រព្រឹត្តបទល្មើស។
- វិភាគដំណើរនៃការប្រែប្រួលរបស់ឧក្រិដ្ឋភាពដែលក្នុងនោះមានបទល្មើស Determinare របស់បទល្មើសមូលហេតុល្មើស ។ល។
- ធ្វើសំណើសំរាប់យកទៅអនុវត្តដើម្បីទប់ស្កាត់បទល្មើស។

ខ. ប្រភេទវិធីសាស្ត្រ

ឧក្រិដ្ឋវិទ្យាស្រាវជ្រាវ ជាប្រភេទមួយក្នុងចំណោមការស្រាវជ្រាវទាំងអស់ក្នុងសង្គមហើយទាមទារនូវការយល់ដឹងដ៏ទូលាយបំផុតចំពោះបាតុភូតសង្គម។ វិធីនេះប្រតិបត្តិក្នុងការស្រាវជ្រាវដោយប្រើប្រាស់គ្រប់ វិធីគ្រប់មធ្យោបាយដើម្បីស្រាវជ្រាវនូវអ្វីដែលកើតឡើង ហើយទាក់ទងនឹងឧក្រិដ្ឋភាព។ ក្នុងការអនុវត្តន៍ វិធីស្រាវជ្រាវត្រូវ បែងចែកជាពីធំៗ។ ផ្នែកទីមួយ គឺជាវិធីដែលប្រើប្រាស់ចំណេះដឹងផ្នែកទ្រឹស្តី និង ផ្នែកទីពីរ ជាវិធីដែលពិនិត្យមើលភាពជាក់ស្តែងក្នុងសង្គម។

១-ផ្នែកទី១ ក្នុងវិធីនេះបែងចែកជាប្រភេទៈ

ក-1- ការប្រមើមើល (Abstract)

ខ-1- សម្មតិកម្ម (Gypothesis)

គ-1- ប្រព័ន្ធវិធី (Systemalics)

ឃ-1- ប្រវត្តិវិធី (History)

ង-1 - ការប្រៀបធៀប (Camparency)

ច-1- ស្ថិតិ (Starstitics)

ក-1-ការប្រមើមើល : វិធីនេះចាំបាច់ត្រូវការស្ទាប់ស្ទង់ក្នុងការគិតចំពោះការរៀបចំស្រាវ-ជ្រាវការប្រើប្រាស់ចំណេះដឹងសំរាប់ការស្រាវជ្រាវ។ តែការប្រមើមើលបែបនេះត្រូវចែកជាពីរខណៈ។ ខណៈទីមួយ ត្រូវប្រើប្រាស់ ទ្រឹស្តី ប្រើវិធីសាស្ត្រគ្រឿងបរិក្ខា និងកំណត់ទិសដៅសំរាប់ស្រាវជ្រាវ។

ខណៈទីពីរ ត្រូវស្វែងយល់ពីបាតុភូតឧក្រិដ្ឋភាព និងភាពវិវត្តន៍របស់វា។ ប្រសិនបើការស្រាវជ្រាវពុំបានគិតគូដល់បញ្ហាស្ថាបស្ងង់នេះទេនោះ លក្ខណៈសម្បត្តិនៃការស្រាវជ្រាវពុំបានគ្រប់ជ្រុងជ្រោយ ហើយនឹងអាចពុំទទួលបានជោគជ័យទៀតផង។ តែគួរចងចាំថា វិធីនេះមានភាពជាអរូបីយ៉ដែលអ្នកស្រាវជ្រាវដាច់ខាត់ត្រូវតែពិចារណាជាលើកដំបូង។

ខ-1- សម្មតិកម្ម : ជាបញ្ហាចំបងរបស់អ្នកស្រាវជ្រាវ ដែលបង្កើតឡើងដើម្បីយកទៅសិក្សាស្រាវជ្រាវ។ ក៏ប៉ុន្តែសម្មតិកម្មមិនអាចបង្កើតក្រៅពីលក្ខខណ្ឌនៃមជ្ឈដ្ឋានស្រាវជ្រាវ ឬក៏ហួសពីព្រំដែនបានឡើយ។ ដូច្នេះ សម្មតិកម្មអាចបង្កើតឡើងនៅក្នុងលក្ខខណ្ឌពីរយ៉ាង។ លក្ខខណ្ឌទី១ ត្រូវស្របនឹងលក្ខណៈស្រាវជ្រាវបែបឧក្រិដ្ឋវិទ្យា។ លក្ខខណ្ឌទី២ ការបង្កើតសម្មតិកម្មត្រូវស្ថាបស្ងង់សមត្ថភាពនៅពេលអនុវត្ត ស្រាវជ្រាវ និងជាពិសេសឱ្យសមស្របទៅតាមសំណើ ឬក៏អនុសាសន៍របស់អ្នកឯកទេស។

គ-1- ប្រព័ន្ធវិធី : វិធីនេះអនុវត្តស្រាវជ្រាវលើកម្មវត្ថុដែលមានការទាក់ទងពីមួយទៅមួយ។ ជាពិសេសទំនាក់ទំនងឧក្រិដ្ឋភាព និងសង្គម។ ការស្រាវជ្រាវតាមប្រព័ន្ធវិធីមានទំនាក់ទំនងកត្តាពីរយ៉ាង។ ទំនាក់ទំនង ទីមួយ គឺវិភាគអត្តសញ្ញាណឧក្រិដ្ឋភាព ដែលជាមជ្ឈដ្ឋានក្នុង និង ទីពីរ វិភាគមូលហេតុ ដែលជាមជ្ឈដ្ឋានក្រៅជំរុញឱ្យប្រព្រឹត្តបទល្មើស។ ដូច្នេះប្រព័ន្ធវិធីជាផ្លូវស្រាវជ្រាវមួយដែលឧក្រិដ្ឋវិទូតែងតែអនុវត្ត។

ឃ-1- ប្រវត្តិវិធី : គឺធ្វើការស្រាវជ្រាវ តាមសម័យកាលរបស់សង្គម។ ការសិក្សាបែបនេះត្រូវការពេលវេលាក្នុងដំណាក់កាលដែលធ្វើការស្រាវជ្រាវ។ ឧទាហរណ៍ : ឧក្រិដ្ឋភាពដែលបានកើតក្រោមរបបសង្គមរាស្ត្រនិយម ឬក៏សម័យរដ្ឋកម្ពុជា។ ការសិក្សាឧក្រិដ្ឋភាពក្នុងសម័យនីមួយៗមានសារៈប្រយោជន៍ឱ្យដឹងការវិវត្តន៍របស់ឧក្រិដ្ឋភាពបែបណាខ្លះកើន ឬថយចុះ និងបណ្តាលមកពីមូលហេតុអ្វីខ្លះ។ វិធីនេះរីកចំរើននៃជំនាន់បង្កើតសាលាវិជ្ជាជីវៈប្បាប់ក្នុង ស.វ ទី ១៤។

ង-1- ការប្រៀបធៀប : ក្នុងការសិក្សាស្រាវជ្រាវ អ្នកស្រាវជ្រាវប្រើវិធីនេះក្នុងគោលបំណង ធ្វើការប្រៀបធៀបឧក្រិដ្ឋភាពក្នុងមជ្ឈដ្ឋានសង្គមទៅតាមតំបន់តាមប្រទេស។ល។ វិធីនេះធ្វើការប្រៀបធៀបទាំងបរិមាណឧក្រិដ្ឋភាព និងស្ថានភាពសង្គម។ ក្រៅពីនេះប្រៀបធៀបផង

ដែរនូវអ្នកប្រព្រឹត្តបទល្មើសដូចជា ភេទ អាយុ ជនជាតិ។ លទ្ធផលបានមកពីការវិភាគអាចឱ្យដឹងលក្ខណៈពិសេសរបស់ឧក្រិដ្ឋភាពនៅតាមតំបន់នីមួយៗ។

ច-1- ស្ថិតិវិធី : ការប្រើប្រាស់ស្ថិតិវិធី គឺជាការប្រមាណទៅលើទំហំនៃឧក្រិដ្ឋភាព។ តែវិធីនេះអនុវត្តទៅ តាមគោលការណ៍ពីរសំខាន់ៗគឺ : ទីមួយ ត្រូវយកបរិមាណឧក្រិដ្ឋភាពទៅតាមធាតុផ្សំបទល្មើសដែលដូចគ្នា។ ទីពីរ ត្រូវគិតថេរៈវេលាក្នុងកំឡុងពេលច្រើនឆ្នាំ។ ឧទាហរណ៍: សម្មតិកម្មដាក់ឱ្យស្រាវជ្រាវពីឧក្រិដ្ឋភាពអនីតិជនគិតពី អាយុ១២ឆ្នាំ ទៅ១៤ឆ្នាំ។ ការកំណត់បែបនេះអាចឱ្យដឹងពីស្ថានភាពឧក្រិដ្ឋភាពទោះបីមានការវិវត្តន៍បែបណាក៏ដោយ។

២.ផ្នែកទី២

ឧក្រិដ្ឋវិទ្យាស្រាវជ្រាវប្រើវិធីនេះសំរាប់វិភាគបាតុភូតសង្គមក្នុងលក្ខខណ្ឌក៏ច្បាស់លាស់ទៅតាមទីកន្លែង និងពេលវេលា។ វិធីនេះបែងចែកជា :

ក-2- សិក្សាឯកសារ

ខ-2- ការសាកសួរ

គ-2- ការតាមដាន

ឃ-2- ការពិសោធន៍

ក-2- ការសិក្សាឯកសារ : ឯកសារជាមធ្យោបាយដ៏សំខាន់ សំរាប់ធ្វើការស្រាវជ្រាវ។ ឯកសារទាំងនេះមានភាពផ្សេងៗគ្នាដែលបានមកពីរបាយការណ៍ស្ថិតិ ឯកសារក្តីព្រហ្មទណ្ឌពាក្យបណ្តឹង ឯកសារកោសល្យវិច្ច័យ ព្រឹត្តិប័ត្រផ្សេងៗដែលទាក់ទងនឹងឧក្រិដ្ឋភាព ។ល។

ខ-2- ការសាកសួរ : មានពីរយ៉ាងដែលត្រូវសួរយកពិតមានគឺ ប្រើទំរង់ ឬបទសំភាសន៍។ ទំរង់ជាទ្រង់ទ្រាយនៅលើក្រដាសគំរូ និងមានចន្លោះសំរាប់បំពេញ។ សំភាសន៍ជាការសន្ទនាជាមួយបុគ្គលដែលបានប្រព្រឹត្តបទល្មើសជាមួយញាតិមិត្តឧក្រិដ្ឋជនជាមួយមន្ត្រីនគរបាលយុត្តិធម៌ ។ល។

គ-2- ការតាមដាន : (ការអង្កេត) ការតាមដានមានច្រើនយ៉ាងដែលប្រើសំរាប់ស្រាវជ្រាវ។ តែឧក្រិដ្ឋវិទ្យាស្រាវជ្រាវជ្រើសរើសយកការតាមដានបីប្រភេទមកអនុវត្ត :

- អ្នកតាមដាន : ត្រូវអង្កេតទៅលើសកម្មភាពសហការីរបស់ខ្លួន និងសិក្សាអំពីការវិវត្តន៍ ប/ទ ហើយឆ្លុះបញ្ចាំងក្នុងច្បាប់ និងការអនុវត្តន៍ជាក់ស្តែង។

- អ្នកតាមដានផ្ទាល់: មានន័យប្រហាក់ប្រហែលដូចខាងលើ តែជាសកម្មវិភាគក្នុងមជ្ឈដ្ឋានជាក់ស្តែង។
- អ្នកចូលរួមតាមដានមានអ្នកឯកទេសផ្សេងៗទៀតក្នុងវិស័យសង្គម ដូចជាអ្នកចិត្តសាស្ត្រ ជីវសាស្ត្រ...ល។

ឃ-2- ការពិសោធន៍ : នៅក្នុងឧក្រិដ្ឋវិទ្យា អនុវត្តវិធីពិសោធន៍សំរាប់ស្ថាបស្ថង់មើលកម្មវត្ថុដែលត្រូវស្រាវជ្រាវ។ ប៉ុន្តែការប៉ាន់ស្មានដោយគិតទុកជាមុននេះ គឺកំណត់ទៅលើមូលហេតុ និងលក្ខខណ្ឌដែលជំរុញឱ្យមានការប្រព្រឹត្តបទល្មើស និងកំណត់ទៅលើវិធានការព្រមានឧក្រិដ្ឋភាព[1]។

សរុបសេចក្តីមក គ្រប់វិធីដែលអនុវត្តធ្វើការស្រាវជ្រាវឧក្រិដ្ឋភាពវាអាស្រ័យទៅនឹងកម្មវត្ថុ និងទិសដៅនៃការស្រាវជ្រាវ។ ដូច្នេះក្នុងគំរោងស្រាវជ្រាវត្រូវកំណត់ និងបែងចែកឱ្យបានច្បាស់លាស់។ យើងអាចចែកដូចតទៅ :

- កំណត់ និងបញ្ជាទិសដៅស្រាវជ្រាវ
- បង្កើតសម្មតិកម្មឱ្យសមស្របតាមលក្ខខណ្ឌ
- រិះរកគ្រប់មធ្យោបាយ ដើម្បីអនុវត្តភារកិច្ចនៃការស្រាវជ្រាវឱ្យមានប្រសិទ្ធិភាព។

៤. ឧក្រិដ្ឋវិទ្យានៅកម្ពុជា

ជាទូទៅឧក្រិដ្ឋវិទ្យានៅកម្ពុជាមានភាពអន់ថយ និងពុំមានការវិវត្តន៍គួរឱ្យចាប់អារម្មណ៍សោះជាពិសេសឧក្រិដ្ឋវិទ្យាស្រាវជ្រាវតែម្តង។ តាមធម្មតាឧក្រិដ្ឋវិទ្យាស្រាវជ្រាវត្រូវបានធ្វើឡើងដោយសហការីនៃវិទ្យាស្ថានវិទ្យាសាស្ត្រ និងធ្វើឡើងដោយស្ថាប័នឧត្តមសិក្សា។ នៅវិទ្យាស្ថានបរទេសដែលធ្វើការសិក្សាស្រាវជ្រាវផ្នែកឧក្រិដ្ឋភាពមានដូចជា វិទ្យាស្ថានវិទ្យាសាស្ត្រស្រាវជ្រាវពង្រឹងច្បាប់នៃមហាអយ្យការ វិទ្យាស្ថានរដ្ឋ និងច្បាប់សាខាមួយនៃក្រសួងមហាផ្ទៃ ។ល។ ចំពោះស្ថាប័នឧត្តមសិក្សត្រូវបានធ្វើការស្រាវជ្រាវដោយផ្នែកមួយនៃមហាវិទ្យាល័យនីតិសាស្ត្រ[2] ។ បើយើងក្រឡេកមើលនៅកម្ពុជាវិញលក្ខណៈ នៃការស្រាវជ្រាវបែបនេះ ពុំមានទេជាពិសេសនៅស្ថាប័នឧត្តមសិក្សា។

---

[1] មើល Duverger M.Methodes des sciences sosiales. Paris Presses. Universitaire s de France 1964. P. 356

[2] នៅបរទេសមហាវិទ្យាល័យនីតិសាស្ត្រមានទីចាត់ការដែលនៅក្នុងនោះមានមុខវិជ្ជាបីផ្សេងគ្នា : នីតិព្រហ្មទណ្ឌ ឧក្រិដ្ឋវិទ្យា និងនីតិប្រតិបត្តិព្រហ្មទណ្ឌ។

ការបណ្តុះបណ្តាលចំណេះដឹងផ្នែកឧក្រិដ្ឋវិទ្យាដល់អ្នកជំនាញក៏ពុំមានសកម្មភាព។ ដូច្នេះទាំងទ្រឹស្តី និងការអនុវត្តន៍ ឧក្រិដ្ឋវិទ្យានៅកម្ពុជាយើងពុំមានការវិវឌ្ឍន៍ឡើយ។

វិធានការទាំងឡាយដែលបានធ្វើការប្រឆាំងនឹងបទល្មើស បើគ្មានការវិភាគរកមូលហេតុតាមទស្សនៈឧក្រិដ្ឋវិទ្យាទេក៏ពុំមានប្រសិទ្ធិភាពដែរ។ ហេតុដូច្នេះហើយបានជាបទល្មើសមួយចំនួនចេះតែកើតមានឡើង និងកើនឡើងជាលំដាប់។

ចំពោះឯកសារ ដែលបានស្រាវជ្រាវក៏មានការខូតខាត និងសឹងតែពុំមានសោះ។ បើមានឯកសារមានតែឯកសារដែលទាក់ទងនឹងការអនុវត្តន៍ជាក់ស្តែងប៉ុណ្ណោះ។

កត្តាដែលធ្វើឱ្យឧក្រិដ្ឋវិទ្យា នៅកម្ពុជាមានភាពអន់ថយមានមូលហេតុច្រើនយ៉ាង តែយើងលើកយកកត្តាសំខាន់ៗដូចជា :

- កង្វះខាតចំណេះដឹងផ្នែកឧក្រិដ្ឋវិទ្យា។
- កង្វះខាតឯកសារស្រាវជ្រាវ និងសំភារៈស្រាវជ្រាវ។
- ចាត់ទុកថាឧក្រិដ្ឋវិទ្យាពុំមានសារៈប្រយោជន៍សំរាប់យកទៅអនុវត្ត។
- ពុំមានស្ថាប័នរដ្ឋណា ដែលទទួលខុសត្រូវលើការស្រាវជ្រាវឧក្រិដ្ឋភាព។

ដូច្នេះដើម្បីឱ្យ ឧក្រិដ្ឋវិទ្យានៅកម្ពុជាទទួលបានភាពរីកចំរើនលុះត្រាបំពេញនូវ ការកង្វះខាតដូចបានរៀបរាប់ខាងលើ និងមានការទទួលខុសត្រូវពីភាគីរដ្ឋ។ បើពុំនោះទេឧក្រិដ្ឋវិទ្យាពុំមានការលូតលាស់ រីឯ វិធានការទាំងឡាយដែលទប់ស្កាត់បទល្មើស ដោយពុំមានការចូលរួមរបស់ឧក្រិដ្ឋ-វិទ្យានឹងទទួលបរាជ័យ។

ម៉្យាងទៀតដើម្បីទទួលបានការរីកចំរើនផ្នែកឧក្រិដ្ឋវិទ្យានៅកម្ពុជាចាំបាច់ត្រូវមានទំនាក់ទំនងជាមួយឧក្រិដ្ឋវិទ្យាបរទេសនៅលើពិភពលោក។ គឺទំនាក់ទំនងដោយធ្វើការផ្លាស់ប្តូរបទពិសោធន៍ធ្វើការប្រៀបធៀបវិធីសាស្ត្រស្រាវជ្រាវ និងផ្លាស់ប្តូរទស្សនៈដោយធ្វើជាអនុសាសន៍សំរាប់យកទៅអនុវត្ត។

ដូច្នេះគួរតែពិចារណាបញ្ហាឧក្រិដ្ឋវិទ្យា និងឧក្រិដ្ឋវិទ្យាភាពនៅកម្ពុជាតើយើងធ្វើយ៉ាងណាឱ្យមានការរីកចំរើនបានល្អ។ ម្យ៉ាងទៀតការទប់ស្កាត់បទល្មើស មិនអាស្រ័យការកំណត់ទោសក្នុងច្បាប់ព្រហ្មទណ្ឌដ៏ធ្ងន់ធ្ងរ ការធ្វើច្បាប់ដោយរឹតបន្តឹងដោយពុំមានមូលហេតុនោះឡើយ។ ទ្រង់ចំនុចនេះ

យើងចង់និយាយថា បច្ចេកទេសធ្វើច្បាប់មានបច្ចេកតាមលក្ខណៈសមស្របដោយរកហេតុផលគ្រប់បែបយ៉ាងជាពិសេសកំណត់បញ្ហា និងផែនការទើបស្រាវជ្រាវជាក្រោយ បើវិភាគអោយស៊ីជម្រៅជាលក្ខខណ្ឌកំរិតបច្ចេកទេសនយោបាយព្រហ្មទណ្ឌរបស់រដ្ឋ។

ឧក្រិដ្ឋភាព

១. និយមន័យ និងយន្តភាព (Definition and Mechanism)

* ឧក្រិដ្ឋភាព គឺជាបាតុភូតសង្គមដែលកើតឡើងល្មើសច្បាប់ព្រហ្មទណ្ឌជារូបភាពរបស់បទល្មើសផ្សេងៗនិងបានប្រព្រឹត្តដោយឧក្រិដ្ឋជនក្រោមមជ្ឈដ្ឋានរបស់សង្គម។ លក្ខណៈសម្បត្តិរបស់ឧក្រិដ្ឋភាពគ្រប់ដំណាក់កាលរបបរបស់សង្គមកម្ពុជាឃើញថា Dynamics[1] របស់វាមានការប្រែប្រួលយ៉ាងខ្លាំងខ្លា។ យើងដឹងហើយថាឧក្រិដ្ឋភាព ជាបាតុភូតសង្គមដូច្នេះសារធាតុរបស់សង្គមជាអ្នកបំពានទំនាក់ទំនងស្របច្បាប់ និងជាអ្នកល្មើសសណ្តាប់ធ្នាប់។ នេះហើយហៅថាផលវិបាកដែលបណ្តាលមកពីមូលហេតុ និងលក្ខខណ្ឌរបស់សង្គម។

ឧក្រិដ្ឋភាព វាបង្កគ្រោះថ្នាក់ដល់សង្គមហើយប្រឆាំងនូវអ្វីដែលច្បាប់បានហាមឃាត់។ ការប្រព្រឹត្តបទល្មើស[2] អាចក្នុងដំណាក់កាលតែមួយឬដំណាក់កាលផ្សេងគ្នា។ ដំណើរការវិវត្តន៍ឧក្រិដ្ឋភាពនិងជំរុញឱ្យមានការផ្លាស់ប្តូរក្រឹត្យក្រមព្រហ្មទណ្ឌ។ រីឯការផ្លាស់ប្តូរច្បាប់នេះជាវិធានការមួយដែលធ្វើការទប់ស្កាត់បទល្មើស។ គួរចាប់អារម្មណ៍ថា កាលណានិយាយពីឧក្រិដ្ឋភាពគឺសំដៅទៅលើភាពអន្តរាយនៃបាតុភូត។ មនុស្សទាំងឡាយប្រព្រឹត្តបទល្មើស គឺមានទិសដៅផ្សេងគ្នាមានដែនកំណត់គោលដៅ ជាពិសេសសមាណនយោបាយខុសគ្នា។ ការបំពានដែលមានលក្ខណៈសម្បត្តិដោយឡែកពីគ្នាធ្វើឱ្យឧក្រិដ្ឋភាពមានបរិមាណ និងគុណភាពខុសៗគ្នា។ ការស្រាវជ្រាវរកភិរតឧក្រិដ្ឋភាពគឺផ្សែងផ្ទាត់ទៅបរិមាណដែលបានប្រព្រឹត្តបទល្មើស ដូចជាអ្នកប្រព្រឹត្តផ្ទាល់ អ្នកចូលរួម ជាដើម។ តែការផ្សែងផ្ទាត់រកបរិមាណឧក្រិដ្ឋភាព យើងអាចកំណត់ជុំវិញបទល្មើសដែលកើតឡើងនៅក្នុងលក្ខណ្ឌដូចតទៅ :

ក. ចំពោះបទល្មើសទាំងឡាយណា ដែលបានបញ្ចប់ដំណើរការក្តីដោយធ្វើការជំនុំជំរះ។

ខ. ចំពោះបុគ្គលដែលបានប្រព្រឹត្តបទល្មើសតែមានសេរីការស្តីពីការទទួលខុសត្រូវចំពោះ

---

[1] ន័យសំដៅកំណើន ឬតំហាយបទល្មើស។ តែសិក្សាតាមរូបមន្ត (មើលទំព័របន្តបន្ទាប់ខាងមុខ)។

[2] បទល្មើសដែលកើតមានក្នុងប្រទេស ទៅតាមតំបន់ ខេត្ត ក្រុង ស្រុក។

មុខច្បាប់ ឬក៏ត្រូវបានលើកលែងទោស ។

គ. ចំពោះបទល្មើដែលពុំបានស្រាវជ្រាវរកឃើញ ។

ឧក្រិដ្ឋវិទ្យាសិក្សាពីឧក្រិដ្ឋភាព ដូចនេះឧក្រិដ្ឋភាពជាកម្មវត្ថុរបស់ឧក្រិដ្ឋវិទ្យាក្នុងការសិក្សាស្រាវជ្រាវ ។ ក៏ប៉ុន្តែការវិភាគឧក្រិដ្ឋភាពមានទស្សនៈពីរហើយទស្សនៈទាំងពីរនេះជាបញ្ហាដ៏សំខាន់នាពេលបច្ចុប្បន្ន ។

* **<u>ទស្សនៈនិតិព្រហ្មទណ្ឌ</u>** (Concept of Criminal Law)

ទស្សនៈនិតិព្រហ្មទណ្ឌ មាននិន្នាការវិភាគនូវហេតុការណ៍ដែលបំពានច្បាប់ព្រហ្មទណ្ឌការវិភាគបទល្មើសចំនុចសំខាន់គឺការវិភាគធាតុធាតុផ្សំនៃបទល្មើស ។

* **<u>ទស្សនៈឧក្រិដ្ឋវិទ្យា</u>** (Concept of Criminology)

ចំពោះឧក្រិដ្ឋវិទ្យា ការវិភាគបទល្មើសគឺក្នុងលក្ខណៈ

+ បុគ្គលិកលក្ខណៈរបស់បុគ្គល

+ ការវិវត្តន៍របស់សង្គម ។

ការអនុវត្តន៍ដើម្បីស្រាវជ្រាវឧក្រិដ្ឋភាពដូចសេចក្តីសន្និដ្ឋាននៃទស្សនៈទាំងពីរ យើងឃើញថាមានលក្ខណៈជាទ្រស្តី និងជាការអនុវត្តន៍ ។ លក្ខណៈជាទ្រស្តីគឺជាមធ្យោបាយបែបអភិញ្ញាណ[1] ចង្អុរបង្ហាញចំពោះការប្រតិបត្តិស្រាវជ្រាវ ។ ការអនុវត្តន៍ជាសកម្មភាពក្នុងដែនកំនត់ដែលបានមកពីទ្រឹស្តីជាអ្នកផ្តល់សមត្ថភាព ។ ការវិភាគរបស់និតិព្រហ្មទណ្ឌចំពោះបទល្មើសអាចឱ្យដឹងនូវសញ្ញាណដែលជាភាពចាំបាច់ និងគ្រប់គ្រាន់ដើម្បីចាត់ទុកថាបុគ្គលណា ដែលបានប្រព្រឹត្តបទល្មើសនឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ព្រហ្មទណ្ឌ ។ រីឯការវិភាគរបស់ឧក្រិដ្ឋវិទ្យាមានទិសដៅរកមូលហេតុ និងលក្ខណៈរបស់បទល្មើស លក្ខណៈសម្បត្តិរបស់បុគ្គលដែលប្រព្រឹត្តបទល្មើស ។ ប្រការដែលអាចឱ្យដឹងបទល្មើស គឺមានសារៈប្រយោជន៍ដើម្បីចាត់វិធានការព្រមានបទល្មើសដែលបានកើតឡើងរួច

---

[1] អភិញ្ញាណ (Fr. Connaissance, Eng. Knowledge) : លទ្ធកម្មចំណេះដឹង ចំពោះនិយ័តភាពធម្មជាតិ. ភាពវិជ្ជមានក្នុងលោក ។ បើនិយមក្នុងវិទ្យាសាស្ត្រ Criminalistics សំដៅកំណត់អត្តសញ្ញាណជនសង្ស័យក្នុងលក្ខណៈបច្ចេកទេស ។ ឧទាហរណ៍. ជន "ក" ជាមុខសញ្ញាដូចខេះ គេត្រូវយកជនសង្ស័យដទៃទៀតមាន ខ. គ. ឃ. ង មកឈរតម្រៀបគ្នាក្នុងអន្លើមួយមានកញ្ចក់ដែលសាក្សីអាចមើលពួកគេឃើញ តែពួកគេមិនអាចមើលសាក្សីបង្ហាញនោះបានឡើយ ។


ហើយ និងការពារបទល្មើសនេះកុំឱ្យកើតមានជាថ្មីទៀតនូវបទល្មើសដដែល។ និងបទល្មើសថ្មីផ្សេងទៀត។

ដូច្នេះតាមគតិយុត្ត ការស្រាវជ្រាវបទល្មើស និង ការវិនិឆ្ឆ័យទោសទៅលើបុគ្គលទាមទារអនុវត្តន៍តាមទស្សនៈឧក្រិដ្ឋវិទ្យា និង ព្រហ្មទណ្ឌជាចាំបាច់។ នៅកម្ពុជាជាពិសេសនាពេលបច្ចុប្បន្នអនុវត្តន៍តាមតែទស្សនៈព្រហ្មទណ្ឌតែប៉ុណ្ណោះ។ ការវិនិឆ្ឆ័យទោសប្រសិនបើពុំយកទស្សនៈឧក្រិដ្ឋ-វិទ្យាមកពិចារណាទេនោះច្បាស់ជាប៉ះពាល់ដល់ចិត្តសាស្ត្ររបស់ឧក្រិដ្ឋជនជាពុំខាន។ ដូច្នេះទោះបីជាច្បាប់ព្រហ្មទណ្ឌមានវិធានការ តឹងរឹងទប់ស្កាត់បទល្មើសយ៉ាងណាក៏ដោយក៏ពុំមានប្រសិទ្ធភាពដែរ។

* **<u>ឃន្តភាពឧក្រិដ្ឋភាព</u>**

ជាប្រព័ន្ធដែលកំនត់ដំណាក់ថ្នាក់នៃសកម្មភាពរបស់បទល្មើស[1] ។ ការសិក្សាឃន្តភាពនេះគឺសិក្សាមជ្ឈដ្ឋានខាងក្រៅ និងបុគ្គលិកលក្ខណៈរបស់បទល្មើស ។ កត្តាទាំងពីរនេះមានឥទ្ធិពលទៅវិញទៅមកក្នុងករណីជំរុញឱ្យប្រព្រឹត្តបទល្មើស។ គួរកត់សំគាល់ថាគ្រប់ដំណាក់នៃការប្រព្រឹត្តបទល្មើសមានមូលហេតុការសំរេចចិត្តប្រព្រឹត្តល្មើស អនុវត្តន៍ការ សំរេចចិត្ត និង ស្ថានភាពតូនាទី។ បុគ្គលដែលប្រព្រឹត្តបទល្មើស គឺអាស្រ័យទៅនឹងដំណាក់កាលនេះហើយនឹងត្រូវបានទទួលឥទ្ធិពលពីមជ្ឈដ្ឋានសង្គម ។

<u>គំនូសបំព្លួយ១-</u>



[1] ជាភាពលំដាប់នៃដំណាក់កាលនៃការប្រព្រឹត្តបទល្មើសដែលចំទុចសំខាន់គឺការសំរេចចិត្ត។ (សូមពិចារណាលើចំណុចសារៈភាពមានដែលមានបទល្មើស)។

ក. <u>មូលហេតុ</u> : ការវិវត្តន៍ក្នុងមជ្ឈដ្ឋានសង្គម (បាតុភូត) វាបង្កមូលហេតុនៃឧក្រិដ្ឋភាព និងគោលដៅប្រព្រឹត្ត។ លក្ខណៈមូលហេតុគឺជាការរំជើបរំជួលផ្នែកស្មារតី ចំពោះឥទ្ធិពល ចំពោះបំណងដែលទាមទារនូវសេចក្តីត្រូវការ ដើម្បីផលប្រយោជន៍ ដើម្បីរំងាប់អារម្មណ៍ ក្រោមស្ថានភាពជាក់ស្តែង។ បន្ទាប់ពីមូលហេតុ គឺបង្កទិសដៅដើម្បីគ្រោងទុកជាមុននូវចំនងចំនូលចិត្ត។

ខ. <u>ការសំរេចចិត្ត</u> : ការសំរេចចិត្តប្រព្រឹត្តបទល្មើស ជាទូទៅត្រូវធ្វើការនិទស្សន៍ឱកាសនិយមមានជំនឿលើសមត្ថភាពថា និងអាចសំរេចបំណងនាពេលខាងមុខ។ ការសំរេចចិត្តរបស់ជនដែលប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពដោយគិតថា :

- គេអាចគេចផុតពីការទទួលខុសត្រូវចំពោះមុខច្បាប់។
- បើទទួលទោសគឺមានលក្ខណៈស្រាលបំផុត។
- ការបង្ហែរអារម្មណ៍ពីមជ្ឈដ្ឋានជុំវិញ។

តាមធម្មតាការសំរេចចិត្តស្ថិតនៅក្រោមស្ថានភាពអាចអនុវត្តបាន។ បើគ្មានជំនឿទេក៏គ្មានការសំរេចចិត្តដែរ។ ជួនកាលការសំរេចចិត្តអាចធ្វើឡើងច្រើនដង និងអាចអនុវត្តភ្លាម។ឬក៏មិនអនុវត្តភ្លាម។ដោយទុកអោយមានចន្លោះពេលមួយរយៈទើបប្រព្រឹត្តបទល្មើស។

គ. <u>ការអនុវត្តន៍</u> : គឺជាការប្រព្រឹត្តផ្ទាល់នូវបទល្មើស។ ភាពជាក់ស្តែងសមិទ្ធិសំរេចចិត្តអាចមានភាពខុសគ្នាពីការគ្រោងទុក។ ដូចជាការផ្លាស់ប្តូរលក្ខណៈ ឬស្ថានភាពខាងក្រៅ។ ឧទាហរណ៍ : អំពើឆក់ប្លន់ ករណីជួបប្រទះការតដៃពីជនរងគ្រោះ។ ករណីបែបនេះការគ្រោងទុកប្រព្រឹត្តអំពើឆក់ប្លន់មានដំណើរការអសកម្ម។ ជួនកាលការសំរេចចិត្ត និងការអនុវត្តន៍មានភាពជាប់គ្នា ឬ កើតមានឡើងក្នុងពេលតែមួយ។

ឃ. <u>តួនាទី</u>[1] : តួនាទីបទល្មើសកើតមានឡើងក្រោយពីឧប្បត្តិហេតុនៃការសំរេចចិត្តថាប្រព្រឹត្ត ល្មើស។ ក្នុងនាមជាតួនាទីល្មើសគឺជ្រើសផ្លូវ ឬ ចាត់វិធានការក្នុងករណីធ្វើយ៉ាងណាដើម្បីឱ្យរួចផុតពី ការទទួលខុសត្រូវចំពោះមុខច្បាប់។ ឧក្រិដ្ឋវិទូបានឱ្យនិយមន័យទៅលើតួនាទីល្មើសតាម

---

[1] ការដាក់តួនាទីជាដំណាក់កាលចុងក្រោយពីព្រោះមានត្រាន់តែឆ្លុះបញ្ចាំងនូវការបែងចែកសកម្មភាពប៉ុណ្ណោះ។ ម្យ៉ាងទៀតតួនាទីអាចកើតក្រោយអំពីការប្រព្រឹត្តហើយដែរ។ ឧទាហរណ៍. ក្រុម "ប្លន់" ដែលពុំមានគំរោងទុកបានគំណត់មុខងារដោះគេចខ្លួន ដូចជាបម្រែងដានពីសមត្ថកិច្ច ការបញ្ជារាល់នាទីជាដើម។

និតិព្រហ្មទណ្ឌថាមិនមែនជាបុគ្គលិកលក្ខណៈរបស់បុគ្គល បន្ទាប់ពីបានប្រព្រឹត្តបទល្មើសណាមួយឡើយ។ ហេតុដូច្នេះហើយបានជាវានានុក្រមរបស់ពាក្យនេះ ប្រើប្រាស់នៅក្នុងយន្តភាពឧក្រិដ្ឋភាពនៅក្នុង ដំណាក់កាលបន្ទាប់ពីការអនុវត្តន៍សេចក្តីសំរេចស្តីពីការប្រព្រឹត្តបទល្មើស។

គំនូសបំព្រួញយន្តភាពខាងលើ បង្ហាញពីដំណាក់កាលនៃសកម្មភាពរបស់បុគ្គលចំពោះការប្រព្រឹត្តបទល្មើស។ តាមទស្សនៈចិត្តវិទូដំណាក់កាលរបស់យន្តភាពបទល្មើសវាទាក់ទងទៅនឹងចិត្តសាស្ត្ររបស់បុគ្គលក្នុងការប្រព្រឹត្តបទល្មើស។ តាមធម្មតាឧក្រិដ្ឋជនមាននិន្នាការដោយជឿជាក់លើខ្លួនឯងថា គ្មានផលវិបាកនឹងកើតមានឡើងចំពោះខ្លួន។ ក្នុងលក្ខណៈបែបនេះហៅថា " យន្តការអព្យាក្រិត្យភាព[1] (Neutralization) របស់ជនល្មើស។ រីឯប្រភេទហេតុការណ៍ " Fact " ដែលមានឥទ្ធិពល (Influence) ទៅលើភាពអត្តនោម័តរបស់ឧក្រិដ្ឋជន មាន :

+ ការបដិសេធនូវការទទួលខុសត្រូវចំពោះមុខច្បាប់ នៅពេលណាដែលបុគ្គលយល់ឃើញថាខ្លួនត្រូវបានទទួលនូវការរងគ្រោះក្នុងកាលៈទេសៈណាមួយ។

+ ឧក្រិដ្ឋជនសង្ឃឹមទុកជាមុនថា[2] នឹងគ្មានព្យសនៈកម្មដល់ខ្លួន និងដល់បុគ្គលដទៃទៀត។

+ ទោសនិងមានការបន្ថយរហូតដល់ផ្តាក់លហុ។

ម្យ៉ាងទៀតការវិភាគយន្តភាព តាមទស្សនៈឧក្រិដ្ឋវិទ្យា ផ្តល់ភាពជាក់លាក់ជាងទស្សនៈព្រហ្មទណ្ឌពីព្រោះ :

១. ដំណាក់កាលមូលហេតុ និងដំណាក់កាលសំរេចចិត្តចាត់ទុកថាជាទង្វើ ក៏ប៉ុន្តែក្នុងច្បាប់ព្រហ្មទណ្ឌ ករណីបែបនេះមិនចាត់ទុកថាជាទង្វើនៃការគ្រោងទុកជាមុនទេ

២. ដំណាក់កាលតួនាទីល្មើស ឧក្រិដ្ឋវិទ្យាចាត់ទុកថា មានទំនាក់ទំនងជាមួយការសំរេចចិត្តប្រព្រឹត្តល្មើស។

ដូច្នេះសរុបសេចក្តីមកតួនាទីល្មើសក្នុងទស្សនៈឧក្រិដ្ឋវិទ្យា គឺជាដំណាក់កាលមានលក្ខណៈល្មើស។បានសេចក្តីថា ការវិភាគបែបឧក្រិដ្ឋវិទ្យាមានភាពតឹងរឹងជាងច្បាប់ព្រហ្មទណ្ឌ។

---

[1] វិភាគតាមចិត្តសាស្ត្រ។ ម. Sykes G. , Mitza D. Technigues of Neutralization : A Theory of Delinguency. American Sociological Review. 1957 N° 22. P. 664

[2] សំដៅទៅលើការមើលឃើញទុកជាមុន មុនការអនុវត្តន៍។

២. <u>វិជ្ជាជីវៈឧក្រិដ្ឋភាព</u> (Professional Criminality)

ជាទូទៅការប្រព្រឹត្តបទល្មើសមានរូបភាពផ្សេងៗគ្នា។ ពេលខ្លះប្រព្រឹត្តដោយបុគ្គលម្នាក់និងជួនកាលប្រព្រឹត្តដោយបុគ្គលច្រើននាក់។ បច្ចុប្បន្ននៅលើពិភពលោកជួបប្រទះបទល្មើសដែលមានលក្ខណៈសម្បត្តិ ជំនាញ[1]។

ចំពោះការប្រព្រឹត្តបទល្មើសដោយឯកឯង ជនល្មើសតែងតែដើរតួជាអ្នកគិតរកមធ្យោបាយនិងជាអ្នកអនុវត្តផ្ទាល់តែម្តង។ តាមការស្រាវជ្រាវរបស់ឧក្រិដ្ឋវិទូបានបង្ហាញឱ្យឃើយថាបទល្មើសដែលមានលក្ខណៈបែបនេះពុំបង្ក គ្រោះថ្នាក់ដល់សង្គមខ្លាំងខ្លាទេ។ ពីព្រោះយើងអាចទប់ស្កាត់ដោយមិនពិបាក និង អាចវែកមុខជនល្មើសបានយ៉ាងឆាប់រហ័ស។

<u>គ្រោះថ្នាក់បំផុតចំពោះសង្គម</u> គឺជាការប្រព្រឹត្តបទល្មើសដោយបង្កើតជាក្រុម ឬជាអង្គភាព។ មុននឹងអនុវត្ត ជនល្មើសត្រូវរៀបចំគំរោង គិតពីមធ្យោបាយដើម្បីយកទៅអនុវត្តរៀបចំតួនាទីក្នុងក្រុម។ បទល្មើសបែបនេះអាចប្រព្រឹត្តដោយបុគ្គលដោយឡែក ឬក៏ជាក្រុមបុគ្គល។ នៅដំណាក់កាលសំរេចចិត្តពួកគេគិតគូពីគំរោងប្រព្រឹត្ត។ ប្រសិនបើបទល្មើសនឹងត្រូវប្រព្រឹត្តដោយបុគ្គលច្រើនរូបគេបែងចែកតួនាទីជាមុនសិន។ ឧទាហរណ៍ : សហចារីម្នាក់ ស្វែងរកកម្មវត្ថុបំពានអ្នកដទៃឡើតធានាមធ្យោបាយ និង ឧបករណ៍ល្មើស និងអ្នកទីបីឧបត្ថម្ភមធ្យោបាយធ្វើដំណើរ ជនទីបួនធានាការពារសន្តិសុខ និងជនទីប្រាំជាអ្នកប្រព្រឹត្តល្មើស។ នេះជាប្រភេទបទល្មើសដែលបុគ្គលរួមគ្នាប្រព្រឹត្ត។


តាមគរុវិជ្ជា បានបញ្ជាក់ឱ្យដឹងថា ការប្រព្រឹត្តបទល្មើសដោយបុគ្គលច្រើននាក់ (ក្រុម) គោលដៅល្មើសមានការផ្លាស់ប្តូរជាញឹកញាប់។ ដូចជាការផ្លាស់ប្តូរមូលហេតុ តួនាទីជាដើម។ ការបញ្ចេញសកម្មភាពដោយអាស្រ័យទៅនឹងការផ្លាស់ប្តូរយន្តភាព វាបង្កើតជាក្រុមសកម្មហើយដែលហៅថា " អង្គការឧក្រិដ្ឋកម្ម " (Organizational Crime) ។ អង្គការឧក្រិដ្ឋកម្ម គឺជាប្រពន្ធ័ទំនាក់ទំនងនៃការបង្កើតអំពើល្មើសរបស់ បុគ្គលម្នាក់ ឬក៏ របស់ក្រុមបុគ្គល។ ពាក្យ " ប្រពន្ធ័ " ជា

---

[1] ក្នុងទោះមាន ឧក្រិដ្ឋជនដែលស៊ីឈ្នួលធ្វើឃាតមនុស្ស។ បើយើងនិយាយក្នុងអង្គការឧក្រិដ្ឋកម្ម អ្នកនេះសំលាប់តែអ្នកថ្នាក់ដឹកនាំ អ្នកល្បីៗក្នុងលោកដូចជាប្រធានាធិបតេយ្យ ជាដើម។ល។

ភាសាក្រិច " Greek " ថា Systemor ហើយមានន័យថាភ្ជាប់ជាចំណងនភាគតូចៗ ។ ក៏ប៉ុន្តែនៅក្នុងឧក្រិដ្ឋវិទ្យាមានអត្ថន័យថា ជាចំណងពីបទល្មើសទៅសកម្មភាពល្មើសហើយក៏មិនមែនជាសកម្មភាពល្មើសធម្មតាដែរ គឺជាអង្គការឧក្រិដ្ឋកម្ម[1] ។ ជាញឹកញាប់អ្នកប្រព្រឹត្តបទល្មើសក្នុងលក្ខណៈអង្គការឧក្រិដ្ឋកម្មមានភាពច្របូកច្របល់ដែលពិបាកឱ្យយើងរកឃើញសកម្មភាពល្មើសពី ។

គំនូសបំព្រួញទី២



គំនូសបំព្រួញនេះនេះឆ្លុះបញ្ចាំងនូវ :

ទីមួយ : ទំនាក់ទំនងបទល្មើសច្រើន ។

ទីពីរ : កាលៈទេសៈដែលអាចនឹងកើតឡើងបទល្មើសនៅដំណាក់កាលមូលហេតុ នៅដំណាក់កាលសំរេចចិត្ត ដំណាក់កាលអនុវត្ត និង នៅដំណាក់កាលតូនាទី ។ ឧទាហរណ៍ ការរៀបចំពោះគំរោងបង្កបទល្មើសចោរកម្ម (Embezzlement) ផ្នែកស៊ីសំណូក[2] (Bribe) របស់បុគ្គល មុខងារ ។ សកម្មភាពល្មើសក្នុងករណីនេះកើតនៅដំណាក់កាលការអនុវត្តន៍ ។

បញ្ហាអង្គការឧក្រិដ្ឋភាព គឺជាបញ្ហាដ៏ធំបំផុត[3] ដែលអ្នកវិទ្យាសាស្ត្រសង្គម មានជាអាទិ៍ ឧក្រិដ្ឋវិទូ អ្នកជំនាញ ឧក្រិដ្ឋនិតិវិទ្យា អ្នកឯកទេសផ្នែកនីតិព្រហ្មទណ្ឌ និងផ្នែកច្បាប់ដទៃទៀត

---

[1] ម. កាសែតរស្មីកម្ពុជា : "Guinness... ឧក្រិដ្ឋកម្ម" ។ ឆ្នាំទី ៧ លេខ១៩៨០ ថ្ងៃអាទិត្យ ទី៣១ ខែតុលា ឆ្នាំ១៩៩៩ (ទំព័រ ខ.៧.) ។

[2] ស៊ីសំណូកជាផ្នែកមួយនៃបទល្មើសចោរកម្ម ។ ច្បាប់ព្រហ្មទណ្ឌបរទេសខ្លះផ្នែកចោរកម្ម មានប្រភេទបទល្មើសដូចជា : លួច ឆក់ ប្លន់ (ស្រាល) រំលោភ លើសេចក្តីទុកចិត្ត ឆរបោក ស៊ីសំណូក.... ។

[3] សមាជទី VI នៃអង្គការសហប្រជាជាតិ "អំពីការព្រមានឧក្រិដ្ឋភាព" នាឆ្នាំ១៩៨០ ក៏មានទាក់ទងនឹងឧក្រិដ្ឋភាពបែបនោះដែរ ។

អ្នកនយោបាយ អ្នកសេដ្ឋកិច្ច អ្នកសង្គមសាស្ត្រ អ្នកចិត្តសាស្ត្រ និង អ្នកការសែត មានក្តីបារម្ភ។ អត្ថន័យអង្គការឧក្រិដ្ឋ ភាពទាក់ទង ទៅនឹងនិយមន័យការបង្កើតបទល្មើស ការបង្កើតក្រុមល្មើស និង អង្គការនេះ ។ គួរកត់សំគាល់ថា ការប្រព្រឹត្តបទល្មើសដោយបុគ្គលច្រើនរូបមិនមែនជាបទល្មើសធម្មតាហើយការប្រព្រឹត្ត នេះទាមទារនូវការព្រមព្រៀងគ្នាជាមុន ស្តីអំពីសកម្មភាពរឿងៗខ្លួនដែលត្រូវបញ្ចេញស្តីពីគំរោងស្តីពីការ រៀបចំប្រព្រឹត្ត ។ល។ ការធ្វើបែបនេះចាំបាច់ត្រូវបង្កើតជាក្រុម។ ការបង្កើតអង្គការឧក្រិដ្ឋកម្ម គឺជាការ ពង្រឹងសកម្មភាពល្មើសក្នុងលក្ខណៈ :

ក. អង្គការឧក្រិដ្ឋកម្ម ត្រូវបិតនៅក្រោមការដឹកនាំ។

ខ. សមាជិករបស់អង្គការឧក្រិដ្ឋ មានតួនាទីច្បាស់លាស់ ។

គ. សមាជិកមិនអាចងាកចេញពីអង្គការនេះបានផ្តេសផ្តាសទេ ។

ឃ. ប្រព្រឹត្តបទល្មើសច្រើនប្រភេទ

ង. មានមធ្យោបាយគ្រប់គ្រាន់ (ជាពិសេសប្រើប្រាក់ដើម្បីធ្វើសកម្មភាព) ។

ដើម្បីឱ្យសមស្របលក្ខណៈនេះជាទូទៅ អង្គការឧក្រិដ្ឋកម្មប្រព្រឹត្តឡើងដោយបុគ្គលច្រើននាក់ និងបទល្មើស ដែលកើតឡើងសុទ្ធតែជាបទឧក្រិដ្ឋ។ ប្រសិនបើធ្វើការវិភាគអង្គការឧក្រិដ្ឋកម្មដែលមាន ឈ្មោះថា “Major ” ឃើញថាមានមូលដ្ឋានរឹងមាំហើយមហាគ្រោះថ្នាក់ ។ ការសិក្សាស្រាវជ្រាវបង្ហាញឱ្យឃើញថា ឧក្រិដ្ឋកម្ម “ Major ”កើតឡើងដោយមានមូលហេតុ។ មានពីរចំនុចដែលត្រូវធ្វើការវិភាគ :

- ទីមួយ : ក្តីឈ្លោភទ្រព្យសម្បត្តិរបស់មនុស្ស។ ភាពមិនស្កប់ស្កល់ចំពោះទ្រព្យធ្វើឱ្យមនុស្សចាប់ផ្តើមចង់បានអំណាច និងជ្រៀតជ្រែកចូលក្នុងអំណាច ។
- ទីពីរ : មានភាពស្មុគស្មាញ។ វាជាលក្ខណៈសីលធម៌របស់បុគ្គលដែលបានទទួលតាំងពីកើត។ ឧទាហរណ៍ កូនបានទទួលផ្នែកសីលធម៌របស់ឪពុកក្រោមបរិយាកាសឧក្រិដ្ឋកម្ម។

យើងដឹងហើយថា អ៊ីតាលីជាប្រទេសល្បីផ្នែក Major ។ តែ Major នៅអ៊ីតាលីចែកជាបីថ្នាក់[1] :

---

[1] តាមលទ្ធផលស្រាវជ្រាវដែលជាអ្នកស៊ើបអង្កេត និងជនជាតិអ៊ីតាលី ។

១-ជាប្រភេទ Major ដែលជ្រៀតជ្រែកទៅក្នុងងំណាចនយោបាយ ។

២-ជាប្រភេទ Major ថ្នាក់ទីពីរ ហើយប្រព្រឹត្តតាមការជួលរបស់អ្នកដទៃ ។

៣- ជាប្រភេទ Major ថ្នាក់ទាប មានជំនាញធម្មតាដូចជាភាវរកម្មជាដើម ។

បច្ចុប្បន្នពេលខ្លះគេហៅអង្គការឧក្រិដ្ឋភាពថារដ្ឋនៅក្នុងរដ្ឋ ។ ប្រការដែលឱ្យឈ្មោះបែបនេះដោយសារតែឧក្រិដ្ឋភាពនេះ ប្រណាំងប្រជែងជ្រៀតជ្រែកចូលក្នុងរចនាសម្ព័ន្ធអំណាចរបស់រដ្ឋធ្វើឱ្យរំខាននយោបាយរដ្ឋ បំផ្លែងយុត្តិធម៌ ។ ប្រទេសដែលអង្គការឧក្រិដ្ឋកម្មនេះជ្រៀតជ្រែក ដូចជាសហរដ្ឋអាមេរិក អាមេរិកឡាទីន អ៊ីតាលី នីការ៉ាហ្គ័រ កូឡុំប៊ី[1] ។ល។

បើនៅកម្ពុជាវិញអង្គការឧក្រិដ្ឋភាពយើងមិនអាចប៉ាន់ស្មានថាមាន ឬ ក៏ពុំមានទេ ។ ពីព្រោះការស្រាវជ្រាវផ្នែកឧក្រិដ្ឋវិទ្យាសឹងតែពុំមាន ។ តែប្រសិនបើប្រភេទទីបីនៃអង្គការឧក្រិដ្ឋកម្មដែលជាប្រភេទថ្នាក់ទាបអាចសន្មត់ថាមាន ។ ព្រោះតាមព្រឹត្តិប័ត្រសារពត៌មានយើងអាចធ្វើការវិភាគទៅលើបទល្មើសមួយចំនួន ។

មធ្យោបាយរបស់អង្គការឧក្រិដ្ឋភាពនាពេលបច្ចុប្បន្ន មានលក្ខណៈល្បឿនល្បឿន ដោយធ្វើសកម្មភាព តាមប្រពន្ធ័ផ្កាយរណប ប្រពន្ធ័កុំព្យូទ័រ ដើម្បីសំរេចគោលបំណងរបស់ខ្លួន ។ ក្នុងករណីដែលឧក្រិដ្ឋភាព មានការវិវត្តន៍បែបនេះយើងត្រូវតែកែរសំរួលច្បាប់ព្រហ្មទណ្ឌឱ្យសមស្របទៅតាមវត្ថុល្មើស បើពុំនោះទេ យើងពុំមានវិធានការណាមួយទប់ស្កាត់បទល្មើសឡើយ ។

៣. ឧក្រិដ្ឋភាព និង ឃាតុភូតសង្គម


យើងបានសិក្សារួចមកហើយ ចំពោះខ្លឹមសារឧក្រិដ្ឋភាព ហើយបានចាត់ទុកថាជាឃាតុភូតសង្គមដ៏គ្រោះថ្នាក់ ។ ប៉ុន្តែវត្តមានឧក្រិដ្ឋភាពសង្គមស្ថិតក្នុងមជ្ឈដ្ឋានផ្សេងៗគ្នា និងទំនាក់ទំនងដោយឡែកពីគ្នា ។

ឧក្រិដ្ឋភាពកើតឡើងក្រោមលក្ខខណ្ឌនៃជីវភាព ។ ជាទូទៅបុគ្គលដែលប្រព្រឹត្តបទល្មើសច្រើនតែសមត្ថជនមានអាយុគ្រប់គ្រប់ក្នុងលក្ខខណ្ឌកំណត់ហើយអាចដឹងនូវអំពើរបស់ខ្លួនដែលបានធ្វើ ។

---

[1] H. Laitinen A. The problem of Contolling Organizational crime II Social changes, Crime and Police (International Conference). Buddapest, 1993. P. 126.

ឧក្រិដ្ឋភាពជាបាតុភូតផ្នែកចិត្តសាស្ត្រ។ នៅពេលដែលបុគ្គលប្រព្រឹត្តបទល្មើសក្នុងស្ថានភាពមិនបង្ខំចិត្តគេហាក់បីដូចជាឃើញកម្មវត្ថុល្មើសធ្វើឱ្យខ្លួនមានភាពរំភើប។



គំនូសបំព្រួញទី ៣

គំនូសបំព្រួញនេះបង្ហាញពីប្រពន្ធ័ដែលទាក់ទងឧក្រិដ្ឋភាព និងបាតុភូតសង្គម។ ប្រសិនបើយើងធ្វើការវិភាគ ឧក្រិដ្ឋភាព និងបាតុភូតសង្គម ក្នុងច្បាប់ឃើញថា សីលធម៌សង្គម និង លក្ខណៈចរិតបុគ្គលមានឥទ្ធិពល ទៅវិញទៅមក។ លើសីលធម៌ល្អ ចរិតលក្ខណៈល្អនោះក្នុងសង្គម និងមានបាតុភូតវិជ្ជមានក្នុងសង្គមនឹងគ្មានឧក្រិដ្ឋភាព ហើយប្រការល្អបែបនេះនឹងមានលក្ខណៈសម្បត្តិល្អ។ តែផ្ទុយទៅវិញក្នុងសង្គមអសីលធម៌ ចរិតលក្ខណៈអាក្រក់ នោះក្នុងសង្គមប្រកបដោយអនាធិប-តេយ្យ ។ កត្តានេះហើយធ្វើឱ្យមានបទល្មើសជាចាំបាច់។

ក. <u>មជ្ឈដ្ឋានសង្គម</u> : ឧក្រិដ្ឋវិទ្យាបានឱ្យនិយមន័យទៅលើមជ្ឈដ្ឋានសង្គម (Social Circle) ថាជាស្ថានភាពសង្គម សកម្មភាពសង្គម ទំនាក់ទំនងសង្គម ដែលប៉ាំពង់ជុំវិញបុគ្គលហើយមានឥទ្ធិពលលើសតិសម្បជៈញ្ញ និងឥរិយាបទរបស់បុគ្គល។ និយមន័យនេះគឺបញ្ជាក់ពី លក្ខ-ខណ្ឌរបស់សង្គមដែលបុគ្គលរងនូវការគាបសង្កត់ក្នុងកំឡុងពេលណាមួយច្បាស់លាស់។

ខ្លឹមសាររបស់មជ្ឈដ្ឋានសង្គម បង្ហាញពីតថភាព នៃការប្រែប្រួលរបស់សង្គមទៅតាមដំណាក់កាល។ ឧទាហរណ៍ : មជ្ឈដ្ឋានសង្គមកម្ពុជា នៅសម័យសង្គមរាស្ត្រនិយម នៅសម័យសាធារណៈរដ្ឋខ្មែរ សម័យកម្ពុជាប្រជាធិបតេយ្យ សម័យរដ្ឋកម្ពុជា និង សម័យបច្ចុប្បន្ន[1]។ នៅតាមដំណាក់

[1] ម. ការសិតរស្មីកម្ពុជា "បញ្ជាមគ្គុទេសន៍ (Guide) ភ្ញាធជំនាញ" ឆ្នាំទី៧ លេខ១៩៧៣ ថ្ងៃសៅរ៍ទី២៣ ខែតុលា ឆ្នាំ១៩៩៩ ខ.៥។

កាលនៃសម័យនីមួយៗបានឆ្លុះបញ្ចាំង ស្ថានភាពសង្គម តាមវិស័យនយោបាយ វិស័យសេដ្ឋកិច្ច វិបត្តិសង្គម... ។ល។ តាមរយៈមជ្ឈដ្ឋានសង្គមអាចឱ្យដឹងចរិតលក្ខណៈបុគ្គល ការវិវត្តន៍ឧក្រិដ្ឋការវិវត្តន៍របស់សង្គម ។ល។ ម្យ៉ាងទៀតមជ្ឈដ្ឋានសង្គមក៏ជាកត្តាមួយដែលមានភាពអវិជ្ជមានហើយជំរុញឱ្យបុគ្គលដោះស្រាយបញ្ហាផ្ទាល់ខ្លួនដោយជ្រើសរើសផ្លូវទុច្ចរិត ។

ដូច្នេះសរុបសេចក្តីមកឧក្រិដ្ឋវិទ្យាស្រាវជ្រាវមជ្ឈដ្ឋានសង្គមគឺវិភាគទៅលើ :

- ចរិតលក្ខណៈរបស់បុគ្គល ។
- ស្ថានភាពសង្គម ។
- ឌីណាមិច (Dynamics) ។
- ជីវភាពសង្គម ។
- ការជ្រើសរើសរបស់បុគ្គល ។

ខ. <u>ឧក្រិដ្ឋភាពក្នុងមជ្ឈដ្ឋានសង្គម</u> : យើងដឹងហើយថាកំណកំណើតឧក្រិដ្ឋភាពមាននៅក្នុងមជ្ឈដ្ឋានសង្គម ។ ក៏ប៉ុន្តែការស្រាវជ្រាវឧក្រិដ្ឋភាពក្នុងមជ្ឈដ្ឋានសង្គម មានភាពស្មុគស្មាញ ដើម្បីបង្កលក្ខណៈងាយស្រួលឧក្រិដ្ឋវិទ្យាស្រាវជ្រាវ បានបែងចែកមជ្ឈដ្ឋានសង្គមជាស្រទាប់ដាច់ដោយឡែកពីគ្នា និងមាន ៤ប្រភេទ :

ក. 1- មេតាមជ្ឈដ្ឋាន (Metacircle) ។

ក. 2- ម៉ាក្រូមជ្ឈដ្ឋាន (Macro Circle) ។

ក. 3- មជ្ឈដ្ឋានកិរិតមធ្យម (Meta~~-~~dium circle) ។

ក. 4- មីក្រូមជ្ឈដ្ឋាន (Micro circle) ។

ក. 1- មេតាមជ្ឈដ្ឋាន : គឺជាស្ថានភាពជាក់ស្តែងនៃទំនាក់ទំនងសង្គមទូទៅក្នុងដំណាក់កាលណាមួយហើយលក្ខណៈនៃការវិវត្តន៍របស់សង្គមមានទ្រង់ទ្រាយទូលាយ ។ ការវិវត្តន៍របស់សង្គមក្នុងស្រទាប់មជ្ឈដ្ឋានបែបនេះមានទាំងផ្នែកសំភារៈ និងផ្នែកស្មារតី[1] ។ ប្រសិនបើយើងធ្វើការវិភាគនា

ប្រជាប្រិយ "វិបត្តិអ្នកស្តាយសញ្ញាប័ត្រក៏ទាយ" ឆ្នាំទី៤ លេខ៨៣ ។

[2] អ្នកច្រាជ្ញជនជាតិ អាល្លឺម៉ង់ (អេរាល់) បានវិភាគទៅលើអរិយធម៌ប្រវត្តិសាស្ត្ររបស់មនុស្សដើម្បីរកមូលហេតុ ឧក្រិដ្ឋភាព ក្នុងស្រទាប់មេតាមជ្ឈដ្ឋាន ។
ម. ទស្សនាវដ្តីប្រជាប្រិយ ឆ្នាំទី៥ លេខ ១១១ ១៦-៣១ កក្កដា ១៩៩៩ (ទំព័រ ៣២-៣៣) អត្ថបទ "សង្គ្រាមក្នុងសតវត្សន៍" ។

សម័យទសវត្សន៍ឆ្នាំ ៨0 ការប្រគួតប្រជែងសញ្ជវុធរវាងរុស្សី និង អាមេរិក ។ ការសាកល្បងនុយក្លេអ៊ែរដែលប៉ះពាល់ដល់បរិស្ថាន និង ជីវិតមនុស្សលោកជំនួញអាវុធឆ្លងប្រទេស ។

ប្រសិនបើយើងក្រឡេកមើល សង្គមកម្ពុជាទសវត្សន៍ឆ្នាំ ៧0 ឬ ក៏នៅទសវត្សន៍ឆ្នាំ ៨0 ដំណាក់កាលនោះ ទាំងនយោបាយ ទាំងសេដ្ឋកិច្ចបានវិវត្ត។ ការប្រែប្រួលនេះបានជំរុញឱ្យពលរដ្ឋយើងរិះរកគ្រប់មធ្យោបាយដើម្បីដោះស្រាយបញ្ហាផ្ទាល់ខ្លួន ក៏ប៉ុន្តែការដោះស្រាយមួយចំនួនវាប្រឆាំងនឹងច្បាប់ ។ គួរកត់សំគាល់ដែលថាឧក្រិដ្ឋភាពក្នុងស្រទាប់មេតាមជ្ឈដ្ឋានមានការប្រែប្រួលដោយមានទ្រង់ទ្រាយ ឬក៏ជារូបភាពធំ ។

ក. 2 - ម៉ាក្រូមជ្ឈដ្ឋាន : ស្រទាប់មជ្ឈដ្ឋានម៉ាក្រូមជ្ឈដ្ឋាន គឺសិក្សាឧក្រិដ្ឋភាពក្នុងសង្គមដោយវិភាគទៅតាមស្ថានភាពសេដ្ឋកិច្ចដែលមានការប្រែប្រួល ។ ម៉ាក្រូមជ្ឈដ្ឋានពុំវិភាគឧក្រិដ្ឋភាពក្នុងមជ្ឈដ្ឋានសង្គមដែលខុសពីស្ថានភាពសេដ្ឋកិច្ចទេ ។ បច្ចុប្បន្ននៅលើទីផ្សារសើរនៃប្រទេសកំពុងអភិវឌ្ឍន៍ ឧក្រិដ្ឋភាពមានដំណើរជាលំដាប់ ។ ឧទាហរណ៍ យើងធ្វើការប្រៀបធៀបប្រទេសមួយចំនួនដែលសេដ្ឋកិច្ច មានការលូត លាស់ដោយពិនិត្យមើលឧក្រិដ្ឋភាពថាតើមានទិសដៅយ៉ាងណា[1] ក្នុងសតវត្ស ៨0 ។

ឆ្នាំ / ប្រទេស	1980	1985
អាល្លឺម៉ង់	6168	6909
បារាំង	4876	6507
អង់គ្លេស	1160	7258
ជប៉ុន	1240	1328
ប៊ុលហ្គារី	282	245
.....	.....	.....

[1] ការរីកចំរើនរបស់សង្គម មានទាំងភាពអវិជ្ជមាន និងវិជ្ជមាន។ ក្នុងតារាងបង្ហាញឱ្យឃើញថាឧក្រិដ្ឋភាពកើនតាមសន្ទុះសេដ្ឋកិច្ច

គំនូសបំព្រួញ ៤

ថ្វីត្បិតនៅបណ្តាលប្រទេសដូចខាងលើសេដ្ឋកិច្ចមានការរីកចំរើនយ៉ាងណាក៏ដោយ ក៏ឧក្រិដ្ឋ-ភាពមិនមានលំនឹងដែរនេះបណ្តាលមកពីរដ្ឋពុំយកចិត្តទុកដាក់ចំពោះពលរដ្ឋទូទៅ។

ក. 3- មជ្ឈដ្ឋានកិរិតមធ្យម : ជាក្រុម ឬ ជាផ្នែកសង្គម។ ដូចជាវណ្ណៈ ឬក៏ឋានៈនៃសង្គម ក្រុមផ្សេងៗនៃសង្គម (សហជីព សហពន្ធ) តំបន់... ។ ល។ ការសិក្សាឧក្រិដ្ឋភាពក្នុងមជ្ឈដ្ឋានកិរិតមធ្យមគឺវិភាគទៅតាមស្ថាន-ភាព ទីកដី នយោបាយ សេដ្ឋកិច្ច វប្បធម៌ ...។ល។ ឧទាហរណ៍ ស្រាវជ្រាវឧក្រិដ្ឋភាពក្នុងទីកដីខេត្តពោធិសាត់ សៀមរាប កំពង់ចាម។ ក្រោយពីបានកំណត់ឧក្រិដ្ឋ-ភាព ហើយត្រូវប្រើវិធីប្រៀបធៀប ឬ វិធីផ្សេងៗរបស់ឧក្រិដ្ឋវិទ្យាដើម្បីស្ថាបស្ងង់មើលបរិមាណឧក្រិដ្ឋភាពក្នុងស្រទាប់មជ្ឈដ្ឋានកិរិតមធ្យម។

ក.4- មីក្រូមជ្ឈដ្ឋាន: គឺជាស្រទាប់មជ្ឈដ្ឋានដែលនៅជុំវិញបុគ្គល គឺវិភាគទៅលើអ្វីដែលមានឥទ្ធិពលទៅលើបុគ្គលក្នុងមជ្ឈដ្ឋានទូទៅ។ ឧទាហរណ៍ : ការប្រាស្រ័យទាក់ទងគ្នារវាងមិត្តភក្តិ ក្រុមគ្រួសារ និង អ្នកចិត្តខាង ។ល។

គ. <u>វិបត្តិសង្គម និង ឧក្រិដ្ឋភាព</u> : សង្គម និងឧក្រិដ្ឋភាពមានទំនាក់ទំនងគ្នាយ៉ាង ជិតស្និទ្ធ ហេតុដូច្នេះហើយការសិក្សារកមូលហេតុឧក្រិដ្ឋភាពចាំបាច់ត្រូវពិចារណាអំពីវិបត្តិសង្គម។ ការសិក្សាវិបត្តិសង្គមតាមបែបឧក្រិដ្ឋវិទ្យាស្រាវជ្រាវ គឺត្រូវវិភាគទៅលើ :

គ.1- ទិដ្ឋភាពសេដ្ឋកិច្ច : ជាដង្កើមរបស់សង្គមដែលត្រូវវិភាគដូចជា ជីវភាពសង្គម សេចក្តីត្រូវការគ្រឿងឧបភោគបរិភោគ និយាយរួម គឺអ្វីៗដែលជាតំរូវការរបស់មនុស្ស និង ចាំបាច់បំផុត។ បើយើងឆ្លុះបញ្ចាំងកម្ពុជាយើងបច្ចុប្បន្នឃើញថា ឧក្រិដ្ឋភាពពេស្យាចារ ឧក្រិដ្ឋភាពពុករលួយ ...។ល។ មានភាពរីកដុះដាលដោយសារតែសេដ្ឋកិច្ចមានវិបត្តិ។ ផលិតកម្ម និង ផលិតផលមិនអាចផ្គត់ផ្គង់ពលរដ្ឋបានទេគ្មានតំលៃលើទីផ្សារ[1] អត្រាប្រាក់គ្មានតុល្យភាព ។ល។

គ.2- ទិដ្ឋភាពនយោបាយ: សំដៅទៅលើអង្គការនយោបាយ ស្ថាបន័ននយោបាយ ទំនាក់ទំនងនយោបាយឥទ្ធិពលនយោបាយ ។ ស្រិនបើយើងក្រឡេកមើលទស្សនៈស្តីពីនយោបាយនៃ


---

[1] ម. ទស្សទាវដ្តីប្រជាប្រិយ "រឿងអាស្រូវទៅពេលពេទ្យស្វាយ" លេខ៧៨ ១-១៥ មីនា ១៩៩៨ (ទំព័រ ១៥-១៧) និងអត្ថបទ "ទីផ្សារត្រកួច ដឹងជិតដាច់ខ្សល់" (ទំព័រ ១៨-២០) ។

សម័យបុព្វកាល របស់ជនជាតិក្រិច (Greek) គឺឱ្យខ្លឹមសារទៅលើការគ្រប់គ្រងរដ្ឋបានសេចក្តីថា រដ្ឋ គឺជាស្ថាបន័កំពូល។ បុគ្គលណាដែលគ្រប់គ្រងសកម្មភាពរបស់រដ្ឋ នឹងមានអំណាចផ្តែកនយោ-បាយនៅប្រទេសនោះ។ ប្រទេសណាដែលមានសេដ្ឋកិច្ច និង សង្គម មានការអន់ថយ គ្រប់វិស័យ រចនាសម្ពន្ធ័ និង តួនាទីឯិតនៅក្រោមអំណាចនយោបាយ ហើយនយោបាយនោះបំរើឱ្យតែវណ្ណៈមួយ ផ្តែកតូច។

គ. 3- ទិដ្ឋភាពអប់រំ : (សីលធម៌ វប្បធម៌ ចំណេះដឹង) : ជាបាតុភូតដែលមានលក្ខណៈលំបាក។ នៅក្នុងនៅក្នុងទ្រឹស្តីទិដ្ឋភាពអប់រំសំដៅ ទៅលើសតិសម្បជញ្ញៈរបស់បុគ្គល កិរិត វប្បធម៌ សាសនា សិល្បៈ ពូជពង្ស នីតិ/បទដ្ឋានរដ្ឋ មនោគមវិជ្ជា ចិត្តសាស្ត្រ ។ល។ ឧក្រិដ្ឋភាព អាចនឹងកើតមានឡើងដោយសារតែកត្តាអប់រំ។ នៅក្នុងសង្គមបើអប់រំមានលក្ខណៈអន់ថយសង្គម នោះនឹងមិនអាចឈានទៅរកការវិវត្តន៍បានឡើយ។ បើពិនិត្យនោកម្តុជាយើងទាំងសីលធម៌ទាំង ចំណេះដឹង ហាក់បីដូជាពុំមានលក្ខណៈល្អប្រសើរសោះ[1] ។

គំនូសចំណ្លាញ៥



គំនូសចំណ្លាញនេះបង្ហាញពីការអប់រំក្នុងសង្គម

[1] សិស្សសាលាភាគច្រើនមិនចូលសាលា។ ម. ទស្សនាវដ្តីប្រជាប្រិយ ឆ្នាំទី៥ លេខ១០៩ ១៦-៣០ មិថុនា ១៩៩៩ (ទំព័រ ១៩-២០) អត្ថបទ "រឿងប្លែកនៅក្នុងសាលារៀន"។

៤. ឌីណាមិច (Dynamics)

Dynamics គឺជាដំណើរការនៃការវិវត្តន៍ការប្រែប្រួលបាតុភូតអ្វីមួយ។ តែឌីណាមិច នៅក្នុងឧក្រិដ្ឋវិទ្យាមានខ្លឹមសារសំដៅទៅលើចលនាវិវត្តន៍របស់ឧក្រិដ្ឋភាព។ ការសិក្សាឧក្រិដ្ឋភាពក្នុងឌីណាមិចបែងចែកដូចតទៅ:

ក. វិភាគធម្មតា : វិភាគធម្មតា មានលក្ខណៈងាយស្រួលគឺត្រូវប្រមូល និងរៀបចំស្ថិតិឧក្រិដ្ឋភាពដោយគិតយកក្នុងកំឡុងពេលមួយឆ្នាំ និងធ្វើការប្រៀបប្រដូចឧក្រិដ្ឋនៃឆ្នាំ.....។ ឧទាហរណ៍ : ឧក្រិដ្ឋភាពឃាតកម្មឆ្នាំ ១៩៩៨ ទូទាំងកម្ពុជាមានចំនួន ១០០ រីឯឧក្រិដ្ឋភាពឃាតកម្មឆ្នាំ ១៩៩៩ ទូទាំងកម្ពុជាមានចំនួន ១៥០... ។ល។

ខ. ប្រពន្ធ័វិភាគ : យើងបានស្គាល់រួចមកហើយប្រព័ន្ធវិធីក្នុងមេរៀនទីមួយ។ តែប្រពន្ធ័វិភាគក្នុងឌីណាមិចគឺយើងធ្វើការប្រៀបធៀបក្នុងកំឡុងពេលច្រើនឆ្នាំ (មាន ៥ឆ្នាំ ១០ ឆ្នាំ) ឬក៏ទៅតាមសំណាក់កាលរីកចំរើនរបស់សង្គម។

គ. កំណើនឧក្រិដ្ឋភាព : គឺធ្វើការគណនាដោយយកចំនួនល្មើសចែក និងបរិមាណទូទៅនៃពលរដ្ឋ ។ល។ ឧទាហរណ៍: បទល្មើសបានកើតឡើងចំនួន ១០០ ក្នុង ១៩៩៥។ យើងធ្វើការប្រៀបធៀបក្នុងវ័យ១៥-២០នៃ ពលរដ្ឋ១.០០០យើងបានដូចតទៅ:

$$\frac{\text{កំណើន } ១០០ \times ១០០\% = ១១\% \text{ នៃបទល្មើសនោះ}}{\text{១០០០}}$$

៥. ឡាក្រិដ្ឋភាព Latens-

Latens ជាភាសាឡាតាំង (Latin) មានន័យថាលាក់មុខមើលមិនឃើញការបិទបាំងភាពខាងក្រៅ។ តែនៅក្នុងឧក្រិដ្ឋវិទ្យាអត្ថន័យនៃពាក្យនេះមានការលំបាកយល់បន្តិច។ ឧក្រិដ្ឋភាព Latens គឺជាឧក្រិដ្ឋភាពដែលមានលក្ខណៈបិទមុខ និងមិនអាចធ្វើការស្រាវជ្រាវបាន[1]។ ដូចជា ឃាតកម្ម ត្រូវបាន បំផ្លែងទៅជាអត្តឃាត មានការបំបិទដានដោយបំផ្លាញចោលនូវសំអាងហេតុគ្រប់យ៉ាងដើម្បីលាក់ស្នាមស្នាមដែលបណ្តាលមកពីសកម្មភាពល្មើស នេះវាជាលក្ខណៈសម្បត្តិនៃការការពារខ្លួនរបស់ជនល្មើសដើម្បីគេចវេសពីការទទួលទោសព្រហ្មទណ្ឌ។

[1] ចំពោះបទល្មើស ដែលបានកើតឡើងហើយ តែការស្វែងរករបស់ស្ថាប័នមានសមត្ថកិច្ចចំពោះបទល្មើសនោះ មិនចេញជាលទ្ធផលបាន។

ជាទូទៅ ឧក្រិដ្ឋភាព Latens អាស្រ័យទីងតួនាទីដែលជាមុខសញ្ញានៃការទទួលខុសត្រូវរបស់ ជនល្មើស ក្នុងនោះមានដូចជា វិជ្ជាជីវៈឧក្រិដ្ឋភាព។ ក្នុងការសិក្សាស្រាវជ្រាវឧក្រិដ្ឋភាពជានិច្ចកាលត្រូវវិភាគ និងកំណត់ភ័ិតឧក្រិដ្ឋភាព Latens។ ឧទាហរណ៍: ការវិភាគភាពវិតត្តន៍របស់ឧក្រិដ្ឋភាពត្រូវការកំណត់អាយុរបស់ ឧក្រិដ្ឋជន ឬក៏សិក្សាតំហាយឧក្រិដ្ឋភាព Latens ទៅតាមស្ថិតិដែលបាន សិក្សា។ ឧក្រិដ្ឋភាព Latens ជាបាតុភូតសង្គមដែលកកើតឡើងអាស្រ័យស្ថានភាព និងលក្ខខណ្ឌក្នុងសង្គម។ បទល្មើសដែលបានប្រព្រឹត្តទៅហើយត្រូវបានត្រៀមលក្ខណៈល្មើសដោយប្រុងប្រយ័ត្ន[1] ទាំងសមត្ថកិច្ច ទាំងស្ថាប័នតុលាការមានការលំបាកក្នុងការស្រាវជ្រាវដើម្បីបញ្ជាក់ថាពិតជាបទល្មើសប្រភេទនោះបានកើតមែន។

ឧក្រិដ្ឋភាព Latens ត្រូវបានបែងចែកដូចតទៅ:

ទីមួយ: គឺជាប្រភេទបទល្មើសដែលបានកើតឡើងហើយ តែសមត្ថកិច្ច ឬស្ថាប័នតុលាការពុំបានទទួលដំណឹងថា កើតមានបទល្មើសទាំងនោះ។ ឧក្រិដ្ឋភាព Latens បែបនេះ នឹងកើតមានឡើងដោយមូលហេតុផ្សេងៗគ្នា ឧទាហរណ៍: បទល្មើសកើតឡើងតែជនរងគ្រោះពុំបានឱ្យដំណឹងអំពីសកម្មភាពល្មើសនោះទៅនគរបាល ឬក៏អ្នកដឹងហេតុការណ៍នេះពុំបានរាយការណ៍ទៅឱ្យសមត្ថ-កិច្ច។ ករណីបែបនេះ ឧក្រិដ្ឋភាព Latens កើតឡើងដោយភាគី រងគ្រោះតែម្តង[2]។ ប្រសិនបើជនរងគ្រោះបានជួយធ្វើអន្តរាគមន៍ក្នុងសង្គមក៏គ្មានបាតុភូត Latens នេះដែរ។

ទីពីរ: គឺជាក្រុមនៃបទល្មើស ដែលសមត្ថកិច្ចបានទទួលដំណឹងតែមានមូលហេតុមួយចំនួនដែលមិនអាចឆ្លុះបញ្ចាំង ឬក៏បញ្ជាក់ថាមានការល្មើសមែន។ Latens ប្រភេទទីពីរនេះមានលក្ខណៈស្មុគស្មាញបន្តិច។ ឧទាហរណ៍ មិនពិនិត្យពាក្យបណ្តឹងស្តីពីបទល្មើសវាយតម្លៃសកម្មភាពល្មើសមិនសមស្របវិភាគបទល្មើសមិនត្រូវ មានមាត្រាច្បាប់ព្រហ្មទណ្ឌ។ល។

សរុបសេចក្តីមក ឧក្រិដ្ឋភាព Latens ជាបាតុភូតដែលមានមូលហេតុបណ្តាលមកពីភាគីរងគ្រោះនិងការវែកមុខជនល្មើសរបស់ស្ថាប័នមានសមត្ថកិច្ច។ ប្រសិនបើយើងវិភាគមើល Latens នៅកម្ពុជាមានច្រើនករណីណាស់ និងមានមូលហេតុផ្សេងៗគ្នា។ មូលហេតុដែលសំខាន់ជាងគេគឺពុំ

---

[1] Lemert Social Pathology N Y 1951 "អាចមានជំនួយដើម្បីពង្រឹងសកម្មភាពល្មើសពីអ្នកដទៃ"។

[2] ពុំមានអន្តរាគមន៍ពីភាគីដែលត្រូវទទួលការរងគ្រោះ ដូចជាសភាពភាយការណ៍ជាដើម។

មានការផ្តល់ពតិមានដល់សមត្ថកិច្ច ឬតុលាការដោយភាគីរងគ្រោះ។ បើយើងវិភាគតាមចិត្តសាស្ត្រ ឃើញថាចិត្តសាស្ត្ររបស់ជនរងគ្រោះ កាលណាទទួលការគំរាមកំហែងពីជនល្មើស ឬត្រូវបានគាបសង្កត់ដោយប្រការណាមួយនោះ ជនរងគ្រោះនឹងមិនអាចធ្វើអ្វីកើតទាំងអស់ជាពិសេសការផ្តល់ពតិមានទៅស្ថាប័នមានសមត្ថកិច្ច[1]។

យើងអាចសិក្សា កំណើន ឬតំហយនៃឧក្រិដ្ឋភាព Lantes តាមឱណាមុិចដោយធ្វើការប្រៀបធៀប ករណីល្មើស តែសមត្ថកិច្ចពុំបានទទួលពតិមាន តែពុំអាចវែកមុខជនល្មើសឃើញ ឬក៏ប្រៀបធៀបទៅនឹងករណីល្មើសផ្សេងៗទៀត។

៦. Determinare-(determination)

Determinare[2] គឺជាពាក្យ Latin មានន័យថាការកំណត់។ នៅក្នុងទស្សនៈវិជ្ជាពាក្យ determinare មានអត្ថន័យដោយសំដៅទៅលើការស្វែងយល់កម្មវត្ថុ ដែលទាក់ទងនឹងមូលហេតុ និងលក្ខខណ្ឌក្នុងសង្គម។ តែនៅ ក្នុងឧក្រិដ្ឋវិទ្យាកាលណានិយាយអំពី deteminare គឺសំដៅទៅលើទំនាក់ទំនងទូទៅ ទំនាក់ទំនងវត្ថុទាំងអស់ ទំនាក់ទំនងកម្មវត្ថុ និងការវិត្តន៍។ ទំនាក់ទំនងនេះមានលក្ខណៈផ្សេងៗគ្នាហើយមានទំរង់ជា ទំនាក់ទំនងមុខងារ ទំនាក់ទំនងស្ថិតិ ទំនាក់ទំនងស្ថានភាព។ល។

ទំនាក់ទំនងមុខងារៈ ជាទំនាក់ទំនងដែលឆ្លុះបញ្ចាំងនូវការវិវត្តន៍ដែលមានលក្ខណៈស្របគ្នាក្នុង បាតុភូត សង្គម។ ឧទាហរណ៍ៈ កំណើនគ្មានការងារធ្វើក្នុងសង្គមជាកត្តាធ្វើឱ្យកកើតបទល្មើសលួច។ សេដ្ឋកិច្ចមានវិបត្តិដោយចុះខ្សោយយើងសង្កេតឃើញថាអំពើពុករលួយកើនឡើងជាលំដាប់។ ខ្លឹមសារនៃ ឧទាហរណ៍ទាំងពីរខាងលើនេះទាក់ទងទៅនឹងមុខងារ ដូចជាគ្មានការងារធ្វើប្រាក់ប្រៀតវត្សន៍តាមកំរិតតួនាទីមិនគ្រប់គ្រាន់។

---

[1] ដូចជាបញ្ហាចាប់ជីវិតយកប្រាក់។ ម. "អត្ថបទការចាប់ជីវិតយកប្រាក់" ទស្សនាវដ្តីប្រជាប្រិយ N° 86, 1-15 កក្កដា ១៩៩៨ (ទំព័រ ១៦-១៧)។ ម. ព្រឹត្តិប័ត្រកម្ពុជា អត្ថបទ "សន្តិសុខសណ្តាប់ធ្នាប់សង្គម មិនទាន់បានចាខាទាំងស្រុងនៅឡើយ" N° 1136 ឆ្នាំទី ២១ (ទំព័រ ៨) ០២-១២-១៩៩៩។

[2] ម. Koichi Miyazawa, Setsuo Miyazawa. Crime Prevention in the urban Community, Page 7. Text "Structural and Situation determinants of crime".

ទំនាក់ទំនងស្ថិតិ: ជាទំនាក់ទំនងដែលទាក់ទងទៅនឹង ការប្រែប្រួលនៃកត្តាមួយដោយអាស្រ័យទៅនឹងកត្តាមួយផ្សេងទៀត។ ឧទាហរណ៍: ក្នុងតំបន់មួយមានបទល្មើសកើនឡើងដោយមានសន្ទុះខ្លាំង។ តែការកើននេះ ដោយសារតែតំបន់នោះមានប្រជាជនកើនច្រើនដែរ។

សរុបសេចក្តីមក ការសិក្សាឧក្រិដ្ឋភាពនៅក្នុង determinare មានខ្លឹមសារដោយសំដៅទៅលើការស្រាវជ្រាវទំនាក់ទំនងនៃការវិត្តន៍ដែលមានឥទ្ធិពលព្រមគ្នា។ ឥទ្ធិពលនេះវាបង្កបទល្មើសក្នុងពេលជាមួយគ្នា។

៧. មូលហេតុ និងលក្ខខណ្ឌ

យើងបានសិក្សាមូលហេតុនៅក្នុងយន្តភាពឧក្រិដ្ឋភាពរួចមកហើយ។ តែពេលនេះយើងសិក្សាមូលហេតុដោយវិភាគលំអិតជាមួយនឹងលក្ខខណ្ឌ។

* មូលហេតុ: ជាប្រភេទមួយនៃទំនាក់ទំនងវត្ថុ និងបាតុភូត ឬក៏ហេតុការណ៍ដែលបង្កឱ្យមានបាតុភូតឱ្យមានការវិត្តន៍។ ជាទូទៅកាលណានិយាយអំពីមូលហេតុ តែងតែវិភាគភ្ជាប់ទៅនឹងផលវិបាក។ លក្ខណៈសំខាន់របស់មូលហេតុមាន:

ទីមួយ: មូលហេតុ ជានិច្ចកាល វាបង្កើតអំពើ និងកាលណាមានអំពើ នឹងមានផលវិបាក។ ក៏ប៉ុន្តែអំពើកើត ដែលកើតឡើងត្រូវស្ថិតនៅក្នុងលក្ខខណ្ឌ។ លក្ខខណ្ឌជាអ្នកផ្តល់លទ្ធភាព ឬក៏ធ្វើការក្រោមបង្គាប់ចំពោះការប្រព្រឹត្តល្មើស។ ប្រសិនបើយើងធ្វើការវិភាគទៅតាមដំណាក់ការនៃយន្តភាពឃើញថាតំបន់ដែលមូលហេតុមានឥទ្ធិពល គឺឋិតនៅក្នុងដំណាក់ការមូលហេតុ និងដំណាក់ការការសំរេចចិត្ត ហើយក៏អាស្រ័យជនរងគ្រោះដែរ[១៩]។

ទីពីរ: ជាបន្តបន្ទាប់ទៅទៀតមានផលវិបាក។ មូលហេតុ ជាប្រក្រតីមានមុនផលវិបាកថ្ងៃត្បិត តែចន្លោះពេលវេលាមានតិចតួចក៏ដោយ។ ហេតុដូច្នេះហើយបានជាការវិភាគបទល្មើសមានសារៈសំខាន់ណាស់ដោយផ្តៀងផ្តាត់ទៅនឹងផលវិបាក។

---

[19] ឧក្រិដ្ឋជនទំលាក់អំហុសទៅជនរងគ្រោះ ដែលបណ្តែតបណ្តោយ ឬច្វេសប្រហែស ដូចជាអង្គុយលេងកន្លែងស្ងាត់ ទីណាមិនតប្បីទៅតាមការអួសទាញជនឧក្រិដ្ឋរឹត.... ។ មើល : Phnom Penh Post "Police Bloter", January 22, (January-26 February-8, 2007), P 10.

ទីបី: ជួនកាលផលវិបាកមិនអាចបណ្តាលមកពីមូលហេតុតែមួយនោះទេ។ គួរចាប់អារម្មណ៍ថាការសិក្សាមូលហេតុនៃឧក្រិដ្ឋភាព មានសារៈសំខាន់ណាស់ក្នុងការវិនិច្ឆ័យទោសទៅលើជនល្មើស និងច្បៀសវាងការដាក់ទណ្ឌកម្មខុសសច្ចៈធម៌។ ប្រសិនបើយើងពុំធ្វើការវិភាគមូលហេតុទេការដាក់ទណ្ឌកម្មនឹងក្លាយទៅជាការបង្ខិតបង្ខំ និងជំរុញឱ្យបុគ្គលរឹតតែប្រព្រឹត្តល្មើសថែមទៀត។

* លក្ខខណ្ឌ : ពាក្យនេះជាភាសា Latin ហៅថា Condition មានន័យថាលក្ខខណ្ឌ ឬ ការទាមទារ។ ជាទូទៅ គេច្រើនតែប្រើជាមួយមូលហេតុ។ លក្ខខណ្ឌ ធាតុចាំបាច់សំរាប់ដើមហេតុ ឬក៏អាចនិយាយផ្សេងទៀតថា ជាកាលៈទេសៈដែលអាចផ្តល់ផលវិបាក។ នៅក្នុងទ្រឹស្តីនៃឧក្រិដ្ឋវិទ្យាបានបញ្ជាក់ ថាកាលៈទេសៈជាកត្តាដែលមានឥទ្ធិពលទៅលើបទល្មើស។ មូលហេតុនៃបទល្មើសជាស្ថានភាពនៃកាលៈទេសៈទូទៅដែលមិនអាចជៀសផុតនូវផលវិបាក។

យើងដឹងហើយថា បទល្មើសកើតឡើងដោយករណីផ្សេងៗគ្នាហើយត្រូវបានទទួលរងនូវការគាបសង្កត់ពីមជ្ឈដ្ឋាន។ តែនៅក្នុងឧក្រិដ្ឋវិទ្យាការគាបសង្កត់មិនមែនមានន័យត្រឹមតែកំលាំងកាយប៉ុណ្ណោះទេ គឺថែមទាំងផ្លូវចិត្តទៀតផង។ ការវិភាគរកមូលហេតុនៃបទល្មើសអាចវិភាគតាមលក្ខណៈមួយដែលហៅថា " បវេណីនិយម "។ បវេណីនិយមជាទស្សនៈនៃការវិភាគបទល្មើសដោយភ្ជាប់ពីមូលហេតុទៅនឹងលក្ខខណ្ឌ។ ឧទាហរណ៍: គេតែងតែលេចឮថាអនីតិជនដែលប្រព្រឹត្តល្មើសច្បាប់ក៏ដោយសារតែមិត្តភក្តិ។

មូលហេតុនៃបទល្មើស មានអត្ថន័យទូលំទូលាយ ហើយអាចចាត់ទុកថាបើគ្មានមូលហេតុគ្មានបទល្មើសឡើយ។ មូលហេតុ គឺជាកំលាំងដែលក្រោមឥទ្ធិពលណាមួយវាបង្កជាការពិត។ ដូច្នេះមូលហេតុច្បាស់លាស់នៃបទល្មើសគឺជាកំលាំងសកម្មដែលទាក់ទាញអារម្មណ៍សំរាប់ប្រព្រឹត្ត។

ក្នុងការស្រាវជ្រាវគេប្រើទ្រឹស្តីបវេណីនិយម[1] ដើម្បីកំណត់ និងវិភាគរកមូលហេតុដែលបណ្តាលឱ្យប្រព្រឹត្តល្មើស។ ឧទាហរណ៍: ជនដែលប្រព្រឹត្តបទល្មើសជាអនីតិជន។ យើងវិភាគទំនាក់ទំនងមូលហេតុ និងលក្ខខណ្ឌដែលជំរុញឱ្យប្រព្រឹត្តល្មើស។


ទីមួយ: គឺបង្កមកពីជនរងគ្រោះ និងទីពីរទាក់ទងសាវតាអនីតិជននោះ។

---


[1] ជាចំនាក់ចំនងថ្នែកស៊ីវិល ចំពោះសកម្មភាពរបស់បុគ្គល និងកម្មសិទ្ធិ។ នៅពេលមានការបំពានណាមួយថ្នែក សិទ្ធិ និងការតក្ងកិច្ច ភាអាចបង្កអោយទៅដាជម្លោះឈានទៅរកបទល្មើស។ ឧទាហរណ៍. បទុប្បន្នចំនាស់ដីធ្លា ជាបញ្ហាសំខាន់ដែលពលរដ្ឋមានការចំនាស់។

ភាពរងគ្រោះដោយសារបទល្មើស គឺជាសារធាតុឋិតនៅក្នុងការវិវត្តន៍នៃការកកើតបទល្មើស។ ដូច្នេះភាពរងគ្រោះនេះជាបញ្ហាទំនាស់នៅក្នុងមជ្ឈដ្ឋានឧក្រិដ្ឋភាព។

គំនូសចំព្រួញបរិណាមនិយម **បវេណីនិយម I**



បវេណីនិយម II



ឧក្រិដ្ឋជន

១. អត្តសញ្ញាណ

* ឧក្រិដ្ឋជនជាកម្មវត្ថុរបស់ឧក្រិដ្ឋវិទ្យាដូច្នេះប្រសិនបើឧក្រិដ្ឋវិទ្យាស្រាវជ្រាវមិនលើកយកបញ្ហានេះមកសិក្សាទេ វាហាក់បីដូចសិក្សាតែមជ្ឈដ្ឋានខាងក្រៅបទល្មើសប៉ុណ្ណោះ។ ម្យ៉ាងទៀត មជ្ឈដ្ឋានសង្គម និងឧក្រិដ្ឋជនមានទំនាក់ទំនងនិងមានឥទ្ធិពលរវាងគ្នាទៅវិញទៅមក។ ការប្រែប្រួលនៃធាតុទាំងពីរនេះ ជាចំណុចដែលមិនអាចធ្វើឱ្យបែកពីគ្នាបាន។ សារធាតុឧក្រិដ្ឋជនឋិតក្នុងទំនាក់ទំនងនៃសង្គមដែលមនុស្សគ្រប់រូបស្វែងរក និងបំពេញនូវសេចក្តីត្រូវការ[1] របស់ខ្លួន។

ការវិភាគឧក្រិដ្ឋជន គឺវិភាគដោយផ្សារភ្ជាប់ទៅនឹងសញ្ញាណសង្គម និងសញ្ញាណជីវៈ។ ទិសដៅនៃការវិភាគបែបនេះ គឺមានគោលបំណងស្វែងយល់សណ្ឋាននៃការប្រព្រឹត្តបទល្មើស និងរួមបញ្ចាំងលក្ខណៈល្មើសក្នុងសង្គមដែលជនល្មើសផ្ទុវទុច្ចរិត។

អត្តសញ្ញាណ[2] បើជាភាសា Latin ហៅ personal និងមានន័យជាលក្ខណៈផ្ទាល់ភាពជាបុគ្គលិកលក្ខណៈរបស់បុគ្គលដែលចូលរួមទំនាក់ទំនងក្នុងសង្គម ដូចជាការវិវត្តន៍របស់សង្គមការីកចំរើនរបស់សង្គមការកសាង ជីវភាព។ល។ ក្នុងទ្រឹស្តីឧក្រិដ្ឋវិទ្យា ការសិក្សាអត្តសញ្ញាណ គឺសិក្សាអត្តសញ្ញាណរបស់ឧក្រិដ្ឋជន។ អត្តសញ្ញាណ ឧក្រិដ្ឋជន ជាអត្តសញ្ញាណរបស់បុគ្គលដែលប្រព្រឹត្តបទល្មើស[3]។ ជាទូទៅអត្តសញ្ញាណរបស់ឧក្រិដ្ឋជនដែលមានមុនប្រព្រឹត្តបទល្មើសមានបី Components[4] :

ក.-ស្ថានសង្គម :គឺជាអត្តសញ្ញាណដែលកំណត់ភាពផ្ទាល់ខ្លួនរបស់បុគ្គលក្នុងលក្ខខណ្ឌណាមួយនៃសសង្គមដែលផ្សារភ្ជាប់ Micri Circle ។

ឧទាហរណ៍: ភេទ អាយុ ចំណេះដឹង ស្ថានភាពគ្រួសារ។

---

[1] Anonia: ជាតម្រូវការមិនអាចខ្វះបាន ប្រសិនជុំយពីនេះបទល្មើសកើតឡើងព្រោះជីវភាពរស់នៅរបស់មនុស្សមានការខ្វះខាត និងម្យ៉ាងទៀតការត្រូវការនេះបង្ក្រាបមិនបានជារឿងរហូត។

[2] Eng. Personality. ក្នុងន័យទ្រឹស្តីឧក្រិដ្ឋវិទ្យា។

[3] ទិយមន័យរបស់ឧក្រិដ្ឋជន គឺកំណត់ដោយផ្នែកទៅលើអត្តសញ្ញាណទូទៅ។

[4] L-Component : ជាផ្នែកណាមួយធាតុទាំងឡាយដែលរួមគ្នាបង្កើតរឿមួយ។

ខ.-តួនាទីសង្គម :ជាប្រភេទនៃសកម្មភាពទាំងឡាយរបស់បុគ្គលនោះក្នុងសង្គមដូចជាតួនាទីរបស់ពលរដ្ឋ ដូចជាមន្ត្រីរាជការ ឬ NGO..... ។

គ. សីលធម៌ចិត្តសាស្ត្រ: ឆ្លុះបញ្ចាំងទំនាក់ទំនងរបស់បុគ្គលនៅក្នុងសង្គម ក្នុងការអនុវត្តន៍ភារកិច្ច ។

អត្តសញ្ញាណឧក្រិដ្ឋជនដែលលើកយកមកនិយាយ និងសិក្សាពេលនេះបានលុះត្រាតែក្នុងករណីណាជននោះបានប្រព្រឹត្តបទល្មើស ហើយជននោះនឹងក្លាយទៅជាប្រធាននៃបទល្មើសក្នុងដែនកំណត់របស់ច្បាប់ព្រហ្មទណ្ឌ ។អត្តសញ្ញាណឧក្រិដ្ឋជនដែលបង្កគ្រោះថ្នាក់ដល់សង្គម គឺជាសារធាតុរបស់អត្តសញ្ញាណ ។ ជាទូទៅត្រូវការបែងចែកឱ្យបានច្បាស់លាស់ និងខុសពីអត្តសញ្ញាណរបស់ពលរដ្ឋធម្មតា ។ ក៏ប៉ុន្តែក៏មានភាពខុសគ្នាដែររវាងអត្តសញ្ញាណឧក្រិដ្ឋជន និងអត្តសញ្ញាណឧក្រិដ្ឋជនដ៏ទៃទៀត ។ ឧទាហរណ៍: ឃាតករមានលក្ខណៈសំគាល់ដែលមើលទៅគួរឱ្យចាប់អារម្មណ៍ គឺភ្នែកមុត ពណិក្រហម... ។ល។ អ្នកឆបោកមានលក្ខណៈ ខាងក្រៅបង្ហាញភាពផ្អែមល្អែម យកចិត្តទុកដាក់អ្នកដទៃ គឺធ្វើបែបណា អោយគេជឿខ្លួន និងទុកចិត្តខ្លួន ។ ក្នុងចំណោមអត្តសញ្ញាណឧក្រិដ្ឋជនទាំងអស់ ប្រសិនបើយកអត្តសញ្ញាណដែលទាក់ទងទៅនឹងសមត្ថភាពមកវិភាគឃើញថាវាគ្រោះថ្នាក់បំផុតសំរាប់សង្គម ។ អសមត្ថជន ដោយជំងឺវិកលចរិត ឬ ក៏អសមត្ថជនដោយជំងឺដែលទាក់ទងទៅនឹងប្រាជ្ញាវាជាសក្តានុពលភាពរបស់ឧក្រិដ្ឋជន[1] ។ ការវិវត្តន៍ផ្នែកប្រាជ្ញាមាន សារៈសំខាន់ណាស់ ហើយបើការវិវត្តន៍នេះមានលក្ខណៈមិនគ្រប់គ្រាន់វាជាហេតុនាំឱ្យបុគ្គលពុំមានការគិតវែងឆ្ងាយចំពោះការទទួលខុសត្រូវនៃសកម្មភាពរបស់ខ្លួន ។ សកម្មភាពប្រព្រឹត្តល្មើសរបស់បុគ្គលអាស្រ័យទៅនឹងកំរិតប្រាជ្ញាកំរិតសម្ភភាពដែលបុគ្គលនោះមាន ។

* ការសិក្សាអត្តសញ្ញាណឧក្រិដ្ឋជន គឺធ្វើឡើងតាមបីដំណាក់កាល:

-អនុវត្តឧក្រិដ្ឋវិទ្យាស្រាវជ្រាវ និងធ្វើការប្រាស្រ័យទាក់ទងជាមួយស្ថាប័នមានសមត្ថកិច្ចដើម្បីប្រមូលពត៍មាន និងស្ថិតិអំពីឧក្រិដ្ឋជន ។ ក្នុងករណីនេះយើងសិក្សាឧក្រិដ្ឋជនដោយបែងចែកទៅតាមប្រភេទបទល្មើសតាមស្ថានភាពបុគ្គលផ្ទាល់របស់ ឧក្រិដ្ឋជន និងតាមសកម្មភាពល្មើសរបស់បុគ្គលនោះ ។

---

[1] Goddard H H Criminal imbecile N.Y, 1915. Human efficiency and levels of intelligence Princenton, 1920.

-សិក្សាអត្តសញ្ញាណឧក្រិដ្ឋជនក្នុងប្រភេទនីមួយៗនៃបទល្មើស ។

ឧទាហរណ៍ :អត្តសញ្ញាណឧក្រិដ្ឋជនក្នុងបទល្មើសរំលោភទទួលផលចោរកម្ម... ។ល ។

- សិក្សាអត្តសញ្ញាណ ក្នុងរង្វង់វ័យរបស់ឧក្រិដ្ឋជន ។

ឧទាហរណ៍: វ័យអនីតិភាព នីតិភាព តាមភេទ ជនជាតិ..... ។ ការសិក្សាអត្តសញ្ញាណឧក្រិដ្ឋជនទៅតាមកិរិតបែបនេះជាមធ្យោបាយរកមូលហេតុ និងល័ក្ខខណ្ឌឧក្រិដ្ឋជន និងជាវិធីមួយផ្តល់លទ្ធភាពដើម្បីចាត់វិធានការព្រមានបទល្មើស ។

តួរឱ្យចាប់អារម្មណ៍ថា ការសិក្សាអត្តសញ្ញាណឧក្រិដ្ឋជនយើងសិក្សាមិនត្រឹមតែសញ្ញាណរបស់វាប៉ុណោះទេ គឺត្រូវសិក្សាសញ្ញាណរបស់បុគ្គលដែលនៅជុំវិញឧក្រិដ្ឋជន និងមានឥទ្ធិពលទៅលើឧក្រិដ្ឋជន ។

* អត្តសញ្ញាណឧក្រិដ្ឋជន ដែលមានលក្ខណៈសង្គម និងជីវៈជាបញ្ហាចំបងដែល អ្នកជំនាញសង្គមសាស្ត្រ អ្នកជំនាញវេជ្ជសាស្ត្រ អ្នកច្បាប់... ។ល ។ ប្រសិនបើយើងមិនវិភាគដោយស៊ីជំរៅចំពោះអត្តសញ្ញាណវាអាចនឹងមានការច្នោះច្នោយ និងហុចលទ្ធផលដ៏អាក្រក់ដល់ការព្រមានឧក្រិដ្ឋភាព ។ ឧទាហរណ៍: អំពើចោរប្លន់នៅកម្ពុជាជាញឹកញាប់ជួបប្រទះនឹងឧក្រិដ្ឋជនដែលមានអាយុពី ១៥ឆ្នាំទៅ ២៥ឆ្នាំ ។ រដ្ឋមានវិធានការទប់ស្កាត់ដោយដកហូតអាវុធជាតិផ្ទុះពីពលរដ្ឋសាមញ្ញនិងពីមន្ត្រីមានសមត្ថកិច្ច និងទុកឱ្យមានប្រើអាវុធដោយករណីលើកលែងខ្លះ ។ ករណីដូចខាងលើនេះយើងយកចិត្តទុកដាក់តែផ្នែក ទំនាក់ទំនងសង្គមប៉ុណ្ណោះ ។ រីឯទំនាក់ទំនងដ៏ទៃទៀតដូចជា ផ្នែកជីវសាស្ត្រ ឬ ផ្នែកចិត្តសាស្ត្រពុំបានវិភាគឡើយ ។ អត្តសញ្ញាណឧក្រិដ្ឋជនដែលទាក់ទងទៅនឹងជីវៈ ឬ ចិត្ត ជាមូលហេតុ ជំរុញឱ្យបុគ្គលប្រព្រឹត្តល្មើសក្នុងលក្ខខណ្ឌនៃមជ្ឈដ្ឋានសង្គម ។

ក្នុងភាពជាក់ស្តែងតែងតែជួបប្រទៈអត្តសញ្ញាណឧក្រិដ្ឋជនមានលក្ខណៈជា Anomalia[1] ។ Anomalia នេះជាអត្តសញ្ញាណបែបជីវៈហើយនៅពេលណាទទួលឥទ្ធិពលខាងក្រៅឥទ្ធិពលនោះជាមូលហេតុបង្កសកម្មភាពល្មើសទៅតាមសេចក្តីត្រូវការរបស់ខ្លួន ។ តាមធម្មតាឧក្រិដ្ឋជនណាដែលមានរូបវន្ត និងចិត្តសាស្ត្រផ្នែក anomalia ឧក្រិដ្ឋជននោះតែងតែស្ថាបស្ថង់មើល និងបញ្ចេញ

[1] Anomalia ជាភាសា Greek: សំរាយមានន័យថា "លក្ខណៈផ្ទៃក។ខុសពីគេ" ។

សកម្មភាពធ្វើយ៉ាងណាឱ្យអារម្មណ៍របស់ខ្លួនបាន រីករាយបានសប្បាយ បានស្កប់ស្កាត់[1] ។ ចិត្តសាស្ត្រ anomalia ដែលសិក្សានៅក្នុងឧក្រិដ្ឋវិទ្យាជាអត្តសញ្ញាណមួយផ្នែករបស់ឧក្រិដ្ឋជន។ ការវិភាគអត្តសញ្ញាណ anomalia វាទាក់ទងទៅនឹងចរិកលក្ខណៈរបស់បុគ្គលផ្នែកវិកលចរិក ភាពប្រមឹក ការញៀនអាភៀន អសមត្ថភាព។ល។ ទ្រឹស្តីឧក្រិដ្ឋវិទ្យាមិនបានសំរាយបញ្ជាក់ចំពោះអត្តសញ្ញាណបែបប្រមឹក ឬ អត្តសញ្ញាណដែលឧក្រិដ្ឋជន ទទួលស្គាល់សកម្មភាពរបស់ខ្លួន។ ឧទាហរណ៍ : ការរងគ្រោះដោយគ្រោះថ្នាក់ហើយទាក់ទងទៅនឹងប្រព័ន្ធសសៃប្រសាទ តែបុគ្គលនោះយល់ច្បាស់ពីសកម្មភាពរបស់ខ្លួន។ ដោយឱ្យរួចខ្លួនពីការទទួលខុសត្រូវចំពោះមុខច្បាប់។ សភាពជាក់ស្តែងជាពិសេសនៅកម្ពុជាយើងគេតែងយល់ថា ការស្រវឹងជាមូលហេតុរួចផុតពីទោសដោយសារតែបុគ្គលនោះពុំដឹងខ្លួនបានធ្វើសកម្មភាពបែបណាឡើយ។ តែយើងជាអ្នកសិក្សាស្រាវជ្រាវទស្សនៈចំពោះករណីខាងលើយល់ ដូម្តេចដែរ?

ការសិក្សាអត្តសញ្ញាណឧក្រិដ្ឋជនត្រូវការចាំបាច់ណាស់ជំនួយពីអ្នកឯកទេសដ៏ទៃទៀត ដូច្នេះប្រការដែលអ្នកស្រាវជ្រាវឧក្រិដ្ឋភាពត្រូវការជំនួយនេះ គឺត្រូវការពត៌មានយ៉ាងក្បោះក្បាយអំពីឧក្រិដ្ឋជន។ ជាទូទៅ ក្នុងការអនុវត្តន៍ត្រូវបែងចែកសញ្ញាណធំៗពិសេសមានដូចជា:

ក. ជីវៈប្រវត្តិ

ខ. ច្បាប់ព្រហ្មទណ្ឌ

គ. ទំនាក់ទំនងក្នុងសង្គម និង សីលធម៌

ឃ. ចិត្តសាស្ត្រ

ង. រូបវន្ត

សរុបសេចក្តីមកការសិក្សាអត្តសញ្ញាណឧក្រិដ្ឋជនគឺសិក្សាជាទូទៅដោយផ្នែកលើលក្ខណៈជីវៈសាស្ត្រ និងសង្គមសាស្ត្រ ដើម្បីស្វែងយល់សារធាតុរបស់ឧក្រិដ្ឋជន[2] ក្នុងមជ្ឈដ្ឋានសង្គម។

---

[1] ម. អត្ថបទ "ឃាតករ ស៊ីសាច់មុនស្ង" ។ ទស្សមាវដ្តីប្រជាប្រិយឆ្នាំមី ៦ លេខ ១១៩. ១៦-៣០ វិច្ឆិកា ឆ្នាំ១៩៩៩ (ទំព័រ ២៩) ។

[2] មួយផ្នែកទាក់ទងទៅនឹងកត្តាអប់រំក្នុងវ័យកុមារភាព។ ម. អត្ថបទ "បញ្ហា និងការអប់រំសំរាប់កុមារត្រូវទទួលខុសត្រូវរួមគ្នា" ព្រឹត្តិប័ត្រអ្នកជា ឆ្នាំមី៦ លេខ ១៣៥. ១៥ មិថុនា ១៩៩៩ (ទំព័រ ១៧-០៩) ។

២. ស្ថានភាពតួនាទី និងសកម្មភាព

ការសិក្សាអត្តសញ្ញាណឧក្រិដ្ឋជន គឺសិក្សាដោយលំអិតវិភាគទៅលើស្ថានភាព តួនាទី និងសកម្មភាពរបស់ឧក្រិដ្ឋជន។

ជាទូទៅ តួនាទីត្រូវបានសិក្សាក្នុងករណីដូចខាងក្រោម:

ក- ការស្រាវជ្រាវបញ្ជាក់ឱ្យឃើញថា ចរិលក្ខណៈរបស់ឧក្រិដ្ឋជនអាស្រ័យទៅនឹង ឋានៈ (L.positio, Eng.position) ដែលបុគ្គលនោះមាននៅក្នុងសង្គម។ តាមធម្មតាឋានៈជាតំណែងមួយ ឬក៏ជាលទ្ធភាពមួយសំរាប់នាំផ្លូវបុគ្គលដើម្បីធ្វើការទំនាក់ទំនង។ ចំណែកឯតួនាទីជាសេចក្តីត្រូវការនៅចំពោះមុខបុគ្គលនិងផ្តាល់ឋានានុក្រមដល់ឋានៈ។ ប្រការដែលយើងសិក្សាស្ថានភាពនៃឋានៈរបស់ឧក្រិដ្ឋជន ពីព្រោះបទល្មើសភាគច្រើនតែងតែប្រព្រឹត្តដោយបុគ្គលមុខងារ[1] (ឧទាហរណ៍ កម្ពុជាបច្ចុប្បន្ន)។ បុគ្គលដែលមានឋានៈក្នុងសង្គម ក្នុងនាមជាមន្ត្រីមុខងារផ្ទៃកលើតួនាទីរបស់ខ្លួនដើម្បីបំពេញកាតព្វកិច្ចអ្វីមួយ បុគ្គលនោះតែងតែយកតួនាទីរបស់ខ្លួនធ្វើជាខែលក្នុងការអនុវត្តន៍។ ករណីនេះចំពោះបុគ្គលមុខងារតែចំពោះពលរដ្ឋធម្មតាវិញឋានៈរបស់គេនៅក្រៅស្ថានភាពកិច្ចការជាផ្លូវការ។ បុគ្គលដែលមិនបំរើការងារតួនាទីដែលជាសេចក្តីត្រូវការនោះផ្តល់ឋានានុក្រមបែបនោះដែរ។ ឧក្រិដ្ឋវិទ្យាស្រាវជ្រាវទៅលើឋានៈតួនាទីរបស់បុគ្គលមុខងារ និងបុគ្គលធម្មតា ដែលបានប្រព្រឹត្តបទល្មើសការវិភាគ អត្តសញ្ញាណឧក្រិដ្ឋជនតាមលក្ខណៈនេះ អាចឱ្យដឹងទំនាក់ទំនងដែលបង្កឱ្យមានបទល្មើសដែលអាស្រ័យទៅលើតួនាទីក្នុងសង្គម។

ខ- តួនាទី គឺជាកត្តាទំនាក់ទំនងរវាងសង្គម និងមនុស្ស។ គឺប្រព័ន្ធទំនាក់ទំនងសំរាប់ផ្តល់លទ្ធភាពឱ្យបុគ្គល និង សង្គម។ ប៉ុន្តែតួនាទីដែលមានដោយបុគ្គលម្នាក់មិនអាចមានដោយបុគ្គលផ្សេងទៀតទេ។ មានន័យថាតួនាទីជាកម្មសិទ្ធិរបស់បុគ្គលម្នាក់មិនអាចអ្នកក្រៅដណ្តើមបានហើយខុសច្បាប់ ឬក៏តួនាទីនោះមានបុគ្គលិកលក្ខណៈត្រួតស៊ីគ្នា។ ការដែលយើងវិភាគតាមតួនាទីក្នុងករណីបែបនេះអាចឱ្យដឹងភាពល្មើសដែលជាអត្តសញ្ញាណក្នុងនាមជាតួនាទី។

សរុបសេចក្តីមកឋានៈក្នុងសង្គម គឺទំនាក់ទំនងផ្សេងៗគ្នានៅក្នុងប្រព័ន្ធសង្គម។ សង្គមវិទ្ធ ចិត្តវិទ្ធ ធ្វើការកត់សំគាល់ថាឋានៈក្នុងសង្គមសំរាប់មនុស្សមានសារៈសំខាន់បំផុតដែលគេគ្រប់គ្នា


---

[1] សំដៅទៅលើបុគ្គលដែលមានតួនាទីក្នុងការបំរើការងារ។

* មនុស្សដែលមានឋានៈក្នុងសង្គម តែមានក្នុងលក្ខណៈផ្ទុយនឹងសេចក្តីត្រូវការក្នុងសង្គម ផ្ទុយនឹងច្បាប់ទំលាប់ ជាបុគ្គលដែលមានទំនាស់នឹងសង្គម។ បានសេចក្តីថាគ្រប់សកម្មភាពរបស់បុគ្គលនោះ ដែលបាន ប្រព្រឹត្តដោយ សំអាងលើឋានៈ និងតួនាទីជាសកម្មភាពល្មើសច្បាប់។ ប្រសិនបើយើងវិភាគតាមឧក្រិដ្ឋវិទ្យា នូវបទល្មើសដែលទាក់ទងនឹងតួនាទីដូចខាងលើនៅក្នុងសង្គមកម្ពុជាឃើញថាមានភាពស្មុគ្រស្មាញ។ ឋានៈរបស់បុគ្គលមានឥទ្ធិពលទៅលើការជ្រើសរើសតួនាទី និងការអនុវត្តន៍។ កុំភ្លេចថាឧក្រិដ្ឋភាពដែលកកើតឡើងដាយមានមូលហេតុដូច្នេះភាគច្រើនជាឧក្រិដ្ឋភាព latens ។ ដូច្នេះវាបង្កគ្រោះបំផុតដល់សង្គមប្រសិនបើយើងពុំធ្វើការរាំងស្កាត់ទេនោះ។

* ម្យ៉ាងទៀតការផ្លាស់ប្តូរ ឬក៏ការប្រែប្រួលឋានៈ និងតួនាទីក្នុងសង្គមក្រោមឥទ្ធិពលនៃមជ្ឈដ្ឋាន ខាងក្រៅ ភាគច្រើនជួបប្រទះតែបទល្មើសក្នុងមជ្ឈដ្ឋានសេដ្ឋកិច្ច[1] ។

មើលក្នុងគំនូសចំណេញ



[1] សំដៅទៅលើបទល្មើសទាំងឡាយណាដែលកើតមានក្នុងរង្វង់ធ្វើពាណិជ្ជកម្ម។

៣. វគ្គីករណ (Classification)

ការសិក្សាឧក្រិដ្ឋជនចាំបាច់ត្រូវមានមូលដ្ឋានសំរាប់ធ្វើការវិភាគដូចជា មូលដ្ឋានផ្នែកទ្រឹស្តី និងផ្នែកអនុវត្តជាក់ស្តែង។ ម្យ៉ាងទៀតការប្រឆាំងនឹងបទល្មើសក៏មិនអាចសិក្សាតែអត្តសញ្ញាណមួយផ្នែកប៉ុណ្ណោះទេ គឺត្រូវសិក្សាដោយបែងចែកឧក្រិដ្ឋជនទៅតាមប្រភេទដោយឡែកពីគ្នា។ ក្នុងកាលៈទេសៈខ្លះអាចបែងចែកឧក្រិដ្ឋជន ទៅតាមប្រភេទដោយឡែកពីគ្នា។ នេះជាបញ្ហាដែលត្រូវដោះស្រាយតាមផ្លូវវគ្គីករណ។

វគ្គីករណឧក្រិដ្ឋជន គឺជាការបែងចែកឧក្រិដ្ឋជនតាមក្រុម។ ក្នុងកាលៈទេសៈខ្លះអាចបែងចែកតាមសញ្ញាណ ប្រជាសាស្ត្រ ដូចជាបុគ្គលដែលមានវ័យជំទង់ វ័យចំណាស់ ស្ត្រីភេទ បុរសភេទ អនីតិជន។ល។ ការសិក្សាដោយបែងចែកឧក្រិដ្ឋជនបែបនេះអាចផ្តល់លទ្ធភាព និងកំណត់ទិសដៅនៃកិច្ចការព្រមានចំពោះ ឧក្រិដ្ឋភាពក្នុងមជ្ឈដ្ឋានដែលចង់បាន។ ក៏ប៉ុន្តែកុំភ្លេចថា វគ្គីករណយកទៅអនុវត្តជាទូទៅសំរាប់ធ្វើការព្រមានឧក្រិដ្ឋភាព ដោយឯកឯងបានទេថ្វីត្បិតតែមានបុគ្គលប្រព្រឹត្តបទល្មើសដែលយើងបានដឹងអត្តសញ្ញាណតាមវិធីនេះក៏ដោយ។

ឧក្រិដ្ឋវិទ្យាស្រាវជ្រាវ បានធ្វើការបែងចែកវគ្គីករណឧក្រិដ្ឋជនជាពីរក្រុមធំៗ ដែលមាន :

ក- សមុទាយភាព[1] : មានន័យថា ការកំណត់ និងបែងចែកឧក្រិដ្ឋភាពជាក្រុម ឬជាពួកតាមសញ្ញាណដោយផ្អែកលើស្ថិតិបទល្មើសក្នុងមជ្ឈដ្ឋានដែលត្រូវការ។ ជាទូទៅការសិក្សាវគ្គីករណតាមប្រភេទនេះមិនត្រូវការវិភាគលក្ខណៈអត្តសញ្ញាណទូទៅរបស់ឧក្រិដ្ឋជន គឺវិភាគដោយលំអិតជាក្រុម តូចៗ និងជាអាទិ៍មាន:

១.ក. ការកំណត់តាមអាយុ ឬភេទ។ ឧទាហរណ៍: ពីអាយុ១៤ ទៅ ១៥ឆ្នាំ ពី១៥ ទៅ ១៦ឆ្នាំ ពី១៦ទៅ ១៧ឆ្នាំ។ ការកំណត់បែបនេះ គឺកំណត់ទៅលើអនីតិជន។ ក៏គិតដូច្នេះដែរ។ គួរកត់សំគាល់ថា វគ្គីករណឧក្រិដ្ឋជនចំពោះអាយុត្រូវគិតជាមធ្យមគិតពីអាយុប៉ុន្មានទៅអាយុប៉ុន្មាន?

---

[1] Fr groupement មានន័យថាការប្រមូលជាពួក ឬជាក្រុមហើយធ្វើការសិក្សាលំអិតក្នុងនោះ។

២.ខ. ការកំណត់តាមស្ថានភាពគ្រួសារ (សង្គម-សេដ្ឋកិច្ច)ដូចជា : កំរិតវប្បធម៌ មុខរបរ ទីលំនៅ (ភូមិ ឃុំ ស្រុក ខេត្ត ក្រុង)មានច្បាស់លាស់ ឬគ្មានច្បាស់លាស់(អចិន្ត្រៃយ៍ បណ្តោះអាសន្ន) ។

៣.ក. កំណត់ពលរដ្ឋ : ការកំណត់ពលរដ្ឋនេះគឺការសិក្សាទៅលើបុគ្គលដែលបានប្រព្រឹត្តល្មើសទៅតាមសញ្ជាតិ តាមជនជាតិ ។ ឧទាហរណ៍ : ពលរដ្ឋកម្ពុជា ពលរដ្ឋ រដ្ឋបរទេស ជនគ្មានសញ្ជាតិ... ។ល។

៤.ក. ការកំណត់ទៅតាមស្ថានភាពរបស់បុគ្គលនៅកាល:ទេស:ប្រព្រឹត្តបទល្មើស ។ ករណីនេះត្រូវវិភាគទៅលើ:

ទីមួយ: កត្តាប្រមឹក ការញៀន។

ទីពីរ: ស្ថានភាពរបស់បុគ្គលជាធម្មតានៅកាល:ទេស:ប្រព្រឹត្តបទល្មើស

ទីបី: ការប្រព្រឹត្តនៅក្នុងពន្ធនាគារ

ទីបួន: ការប្រព្រឹត្តនៅក្នុងពន្ធនាគារ

ទីប្រាំ : ដំណាក់កាលប្រព្រឹត្តបទល្មើស។ ឧទាហរណ៍ ជាលើកទី១ ឬទី២ ... ។ល។

៥.ក. ការកំណត់ទៅតាមទោសរបស់ឧក្រិដ្ឋជន មានដូចជាការប្រព្រឹត្តដោយចេតនា អចេតនា ការកេងប្រវ័ញ្ច ឬប្រព្រឹត្តដោយហឹង្សា..... ។ល។

ប្រភេទនៃវគ្គីករណខាងលើមិនអាចធ្វើការឆ្លុះបញ្ចាំងជាទូទៅបានទេ គឺបានតែមួយផ្នែកប៉ុណ្ណោះ ។ ឧទាហរណ៍ : ការវិភាគឧក្រិដ្ឋជនតាមកំរិតអាយុ ។

តារាងវិភាគ

អាយុ ១៨-២៥	អ្នកមិនសិក្សា	គ្មានការងារ	អ្នកសិក្សា
លួច	៦០	២៥	១៥
ឆបោក	៣០	៤០	៣០
រំលោភលើសេចក្តីទុកចិត្ត	២៥	៦៥	១០

ខ. Typology: គឺជាវគ្គីករណដែលអាចឱ្យដឹងនូវទំនាក់ទំនងរវាងប្រភេទនៃកម្មវត្ថុផ្សេងៗ នឹងអាចឱ្យដឹងទំនាក់ទំនងនៃបាតុភូតខាងក្នុងទាំងអស់។ ការកំណត់អត្ថន័យនេះគឺមានទិសដៅបញ្ជាក់អំពីវគ្គីករណឧក្រិដ្ឋជនមួយផ្នែក ដែលក្នុងនោះនិយាយអំពីលក្ខណៈជំនាញនៃឧក្រិដ្ឋជន។ នៅក្នុងទ្រឹស្តីនៃឧក្រិដ្ឋ-វិទ្យានីតិសព្ទ Typology មានទំនាក់ទំនងទៅនឹងក្រុមឧក្រិដ្ឋជនដែលមានកិរិតខ្ពស់។ ករណីនេះត្រូវមានការបែងចែកសញ្ញាណ និងមូលហេតុ ឧក្រិដ្ឋភាព។ ជាទូទៅ Typology នីមួយៗចាំបាច់ត្រូវតែមានសញ្ញាណ-បាតុភូត និងសញ្ញាណ-មូលហេតុ។ ឧទាហរណ៍ : ការប្រព្រឹត្តអំពើលួចវាជាសញ្ញាណ-បាតុភូត។ ពីព្រោះ ការប្រព្រឹត្តអំពើលួចជាការបំពេញនូវសេចក្តីត្រូវការរបស់បុគ្គលនោះ និងក្រោយពីបុគ្គលនោះយល់ឃើញថាវាជាករណីចាំបាច់ដើម្បីទ្រទ្រង់ស្ថានភាពរបស់ខ្លួន។ ក៏ប៉ុន្តែការប្រព្រឹត្តនោះវាឋិតនៅក្រោមឥទ្ធិពល និងឋិតក្នុងលក្ខណៈនៃមជ្ឈដ្ឋានដែលបានធ្វើការ ក្បៀបសង្កត់ទៅលើបុគ្គលដែលបានប្រព្រឹត្តនោះ[1]។ ដូច្នេះកាលៈទេសៈបែបនេះជាសញ្ញាណ-មូលហេតុ ហើយជាកត្តានឹងសំរាប់ធ្វើការវិនិច្ឆ័យទោស (ដូចជាការបន្ធូរបន្ថយជាដើម)។

ចំពោះ Typology ឧក្រិដ្ឋជន លោក Lombrozo.c. បានធ្វើការវិភាគជាទូទៅហើយបានកំណត់លក្ខណៈពិសេសៗនៃ Typology ដូចជា[2] :

* ឃាតករ : លក្ខណៈពិសេសរបស់ឃាតករអាចឱ្យគេធ្វើការបែងចែកយ៉ាងច្បាស់លាស់ ហើយលក្ខណៈពិសេសទាំងនេះមិនអាចមានភាពដូចឧក្រិដ្ឋជនដទៃទៀត ដូចជាក្រសែភ្នែកមានភាពមុត មានពណ៌ក្រហម..... ។ល។

* អ្នកឆបោក : ជាទូទៅតែងតែមានចរិក និងបង្ហាញភាពខាងក្រៅជាសប្បុរសជន ដោយធ្វើយ៉ាងណាអោយគេមើលទៅហាក់បីដូចជាគួរឱ្យជាទីទុកចិត្ត។ អ្នកឆបោកបើប្រៀបធៀបទៅនឹងអ្នកលួច ឃើញធ្វើការវិភាគទៅហាក់បីដូចជាក្នុងចំណោមវិជ្ជាជីវៈគ្រាន់តែការសិក្សាដោយស៊ីជំរៅ និងទាក់ទងទៅនឹងលក្ខណៈខាងក្នុងរបស់បុគ្គលប៉ុណ្ណោះ។ បានជាមានបញ្ហាលេចឡើងថា "អត្តសញ្ញាណឧក្រិដ្ឋជនជាភាពអរូបិយឬក៏ជាប្រភេទអត្តសញ្ញាណនៃសង្គម[3]"

---

[1] មើលក្នុងមេរៀនទី២ ត្រង់មូលហេតុ និងលក្ខខ័ណ្ឌ។

[2] C. Lombroso "ជោគជ័យថ្មីនៅវិទ្យាសាស្ត្រស្តីពីឧក្រិដ្ឋជន" ១៨៩២ (ទំព័រ ២៣)។

[3] មានមតិខ្លះយល់ថាជាអត្តសញ្ញាណបែបរូបិយ។

អត្តសញ្ញាណឧក្រិដ្ឋជន ជាអត្តសញ្ញាណអរូបិយ ពីព្រោះ :

ទីមួយ : សារធាតុអត្តសញ្ញាណវាទាក់ទងនឹងបទល្មើសក្រោមបាតុភូតនៃមជ្ឈដ្ឋានខាងក្រៅ ក្នុងពេលតែមួយ គឺក្នុងពេលប្រព្រឹត្តបទល្មើសតែម្តង។

ទីពីរ : បុគ្គលដែលប្រព្រឹត្តបទល្មើសភាគច្រើនរៀបចំគំរិយាបថរបស់ខ្លួនឱ្យឋិតក្នុងលក្ខណៈស្របច្បាប់។

ទីបី : អត្តសញ្ញាណជាបុគ្គលិកលក្ខណៈចិត្តសាស្ត្ររបស់រូបវន្ត ពីព្រោះការប្រព្រឹត្តបទល្មើសអាស្រ័យ នឹងស្ថានភាពដែលហុចឱ្យ។

នេះជាការវិភាគដែលទាក់ទងទៅនឹងចិត្តសាស្ត្ររបស់ឧក្រិដ្ឋជន ហើយចិត្តសាស្ត្រនេះស្ថិតនៅក្រោមមជ្ឈដ្ឋានខាងក្រៅដូចជាលក្ខខណ្ឌកាលៈទេសៈ។ ការកកើតបទល្មើសក្នុងលក្ខណៈបែបនេះតាមឧក្រិដ្ឋវិទ្យាចាត់ទុកថាជាបាតុភូតក្នុងសង្គម។